November-2008.qxd 10/22/2008 2:15 PM Page 1


# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី២ ថ្ងៃទី០១-៣០ ខែវិច្ឆិកា ឆ្នាំ២០០៨ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ

លេខ ១៥


## ទោះជាបារម្ភ ឪពុកម្ដាយក៏ត្រូវ កាត់ចិត្តបញ្ជូនកូនទៅឆ្ងាយ

ទំព័រទី១០...




ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

**មាតិកា**



**សកម្មភាព ៥ឆ្នាំ ដំបូងនៃវិទ្យាល័យ សន្តហ្វ្រង់ស្វ័រ** ទំព័រ ៧



**"រួបរួមគ្នា" ទស្សនាវដ្ដីដើម្បីសុខភាព ជនងាយរងគ្រោះ** ទំព័រ ៨



**បណ្ដែតប្រទីប ពិធីបុណ្យ...** ទំព័រ ១៤



SIPAR

**សៀវភៅ ធ្វើអោយអ្នកចេះ**

មានលក់នៅតាមបណ្ណាគារ និងតូបលក់សៀវភៅនានា

023 216 001
siparedition@online.com.kh



កម្មវិធីវិទ្យុ



**អេម៉ានូអែល** សំឡេងពីព្រះសហគមន៍កាតូលិក !

ភ្នំពេញ : FM 99.5 Mhz ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: FM 102.5 Mhz ១០:០០-១១:០០ ថ្ងៃ សៅរ៍/អាទិត្យ
កំពង់ធំ : FM 88.5 Mhz ម៉ោង ១២:០០-១៣:០០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : FM 100.5 Mhz ម៉ោង៦:០០-៧:០០ យប់ថ្ងៃសៅរ៍
កំពត : FM 92.25 Mhz ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

November-2008.qxd 10/22/2008 2:16 PM Page 2

# រូបថតសម្រាប់លេខនេះ



Photo : K. Sovanara

សម័យប្រជុំដំបូងរដ្ឋសភានីតិកាលទី៤ ក្រោម អធិបតីភាពរបស់ព្រះបាទ នរោត្តម សីហមុនី កាលពីថ្ងៃទី២៤ កញ្ញាកន្លងទៅ បន្ទាប់ពីលទ្ធផលបោះឆ្នោតថ្ងៃទី២៧ កក្កដា។ ក្នុងពិធីនោះ មានការចូលរួមពីតំណាងរាស្ត្រគណ-បក្សប្រជាជន គណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ី។ ចំណែកគណ-បក្សសិទ្ធមនុស្សបានខកខាន។ **(ឆ្វេង)**

ការថតរូបជុំគ្នារវាង លោកអភិបាល អេមីល ដេតម្ប លោកឪពុកប្រ៊ុយណូ លោកឪពុកឡេ វ៉ាន់ទីន និងគ្រីស្តបរិ-ស័ទនៅព្រះសហគមន៍ចំប៉ាក្នុងពិធីទទួលស្គាល់លោកសុខណា ជានិស្សិតទេវ-វិទ្យាល័យភូមិភាគភ្នំពេញ។ **(ក្រោម)**



ពិធីប្រកាសទទួលស្គាល់លោកផាន់ បូរី ជានិស្សិតទេវវិទ្យាល័យសម្រាប់ភូមិភាគកំពង់ចាម ដែលពិធីនេះប្រារព្ធធ្វើនៅព្រះសហគមន៍កំពង់ចាម កាលពីថ្ងៃទី១២ តុលា ដែលមានការចូលរួមពីសំណាក់លោកអភិបាលអន់តូនី សាមីស្ទ័សែរាជ គ្រីស្តបរិស័ទជាច្រើន និងមានការលើកទឹកចិត្តពីឪពុកម្តាយរបស់លោកផងដែរ។ **(ក្រោម)**



លោកសុខណា មានអំណរសប្បាយជាខ្លាំងនៅក្នុងពិធីប្រកាសទទួលស្គាល់ជានិស្សិតទេវវិទ្យាល័យសម្រាប់ភូមិភាគភ្នំពេញ។ លោកមានក្តីសង្ឃឹមនឹងការឆ្លើយតបតាមការត្រាស់ហៅរបស់ព្រះជាម្ចាស់។ **(ក្រោម)**



លោកបូជាចារ្យប្រ៊ុយណូ ថតរូបជាមួយនិស្សិតទេវវិទ្យាល័យទាំងបី គឺលោកផាន់ បុរី លោកមួង រស់ លោកសុខណា និងសាត ក្នុងពិធីប្រកាសទទួលស្គាល់សុខណាជានិស្សិតទេវវិទ្យា-ល័យសម្រាប់ព្រះសហគមន៍ភូមិភាគភ្នំពេញនាថ្ងៃទី១៩ តុលា។ **(ឆ្វេង)**



Photo : L. Sovanna



# វិចារណកថា

## លើកទឹកចិត្ត ឱ្យយុវជនបន្តការសិក្សាថ្នាក់ឧត្តម



Photo : P. Samphy

**លោកបូជាចារ្យ អូមែរ ហ្វ៊ីរ៉ាល់ដូ ប្រធានមណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក (CSC)**

បវេសនកាលឆ្នាំថ្មី ២០០៨-២០០៩ ចាប់ផ្តើមហើយ ។ យើងទាំងអស់គ្នាមានសេចក្តីរីករាយជាខ្លាំង ។ ប៉ុន្តែការអប់រំប្រកបដោយគុណភាពដល់យុវជនដ៏ច្រើនលើសលប់ប្រមាណ ៦២% នៃប្រជាជននៅក្នុងប្រទេស គឺជាប្រធានបទដែលត្រូវបំពេញ និងដោះស្រាយជាការចាំបាច់ ។

កត្តាវិជ្ជមានមួយ ដែលគួរឱ្យចាប់អារម្មណ៍ និងបញ្ជាក់ស្មារតី និងការយកចិត្តទុកដាក់របស់យើង គឺនៅឆ្នាំនេះ មានការកើនឡើងដ៏សម្បើមនៃចំនួនសិស្ស ដែលបានបញ្ចប់ការសិក្សា និងបន្តការសិក្សានៅសកលវិទ្យាល័យ ។ នេះបង្ហាញឱ្យឃើញអំពីការយល់ដឹងរបស់ប្រជាជនកម្ពុជាកាន់តែច្រើនឡើងៗ ពីអត្ថ-ប្រយោជន៍នៃការសិក្សាចំពោះកូនចៅរបស់ពួកគេ ។

ចំណុចវិជ្ជមាននេះ ជាការខំប្រឹងប្រែង និងបូជាទាំងកម្លាំងចិត្ត កម្លាំងកាយដ៏សំខាន់របស់គ្រួសារនៅតាមជនបទដើម្បីបញ្ជូនកូនចៅពួកគេ ឱ្យមកបន្តការសិក្សា នៅតាមសកលវិទ្យាល័យនានានៅក្រុងភ្នំពេញ និងទីក្រុងសំខាន់ផ្សេងទៀត ។ តាមការពិត បញ្ហាថវិកា គឺជាឧបសគ្គដ៏សំខាន់សម្រាប់គ្រួសារនៅតាមជនបទក្នុងការបញ្ជូនកូនចៅទៅបន្តការសិក្សា ។ យើងគួរមានតម្លៃតបស្នងខ្លះចំពោះការខំប្រឹងប្រែងរបស់ឪពុកម្តាយដើម្បីឆ្លើយតប និងបំពេញតម្រូវការសិក្សាប្រចាំថ្ងៃរបស់កូន ។

ចំណែករដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ក៏គួរខិតខំប្រឹងប្រែងថែមទៀត ដើម្បីជួយដល់ប្រព័ន្ធអប់រំក្នុងប្រទេស ដែលនៅទន់ខ្សោយនោះ ឱ្យមានការរីកចំរើនឡើង ។

តើអ្នករាល់គ្នាគិតថា មានបណ្តាប្រទេសណាមួយធ្លាប់ត្រឡប់ទៅរកអតីតកាលអន់ថយ នៅពេលដែលប្រជាពលរដ្ឋប្រទេសនោះបានទទួលការអប់រំនៅទូទាំងប្រទេសហើយនោះ ?

នៅពេលចំនួលត្រូវបានជួយឧបត្ថម្ភគាំទ្រដល់គ្រួសាររបស់ពួកគេ នោះការយល់ដឹង នឹងកើតមាននៅពាសពេញ ពិភពលោកព្រមទាំងមានការបរិច្ចាគទៅឱ្យប្រទេសដែលកំពុងអភិវឌ្ឍន៍ ចូរយើងទាំងអស់គ្នា ត្រូវតែបន្តខិតខំប្រឹងប្រែងថែមទៀតនៅលើបញ្ហានេះ ជាពិសេសនៅក្នុងប្រទេសយើងសព្វថ្ងៃនេះ ។

**CSC**
**ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក**
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
**Tel/Fax : (855) 23 224 120;**
**E-mail : csccambodia@gmail.com**
**Website : www.catholiccambodia.org**
ក្រុមប្រឹក្សាភិបាល : លោកអភិបាល អេមីល ដេតម្ប និងលោកអូមែរ ហ្វ៊ីរ៉ាល់ដូ ។
ចាងហ្វាងការផ្សាយ : លោកលី សុវណ្ណា ។
Licence ១៨៣ ពម.ប្រក./២៥-មិថុនា-២០០៧

**មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក** មានចេញលក់នូវស៊ីឌីចម្រៀងវ៉ុលទី៩ ថ្មី ដែលជាចម្រៀងពណ៌នាអំពីតង្វាយដែលថ្វាយទៅព្រះជាម្ចាស់។ តម្លៃលក់ក្នុងមួយស៊ីឌី ៨ ០០០រៀល តែប៉ុណ្ណោះ។ ហេតុដូចនេះ បើប្រិយមិត្តមានចំណាប់អារម្មណ៍ចង់ជាវនោះ សូមទំនាក់ទំនងលេខទូរស័ព្ទ : **០១២ ២៤៤ ៧៧៨៤។/**

## មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក

**សេវាកម្មជាទីគាប់ចិត្ត !** ជារៀងរាល់ថ្ងៃ ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក មានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និងMP3 និងទទួលថតចម្លង CD VCD និងDVD គ្រប់ប្រភេទផងដែរ។ ការថតចម្លងទាំងនេះនឹងធ្វើឡើងប្រកបដោយរូបភាពត្រជាក់ភ្នែកជាមួយនិងសម្លេងច្បាស់ល្អ។ គ្រប់សេវាកម្មទាំងអស់គិតក្នុងតម្លៃសមរម្យ។ ប្រសិនបើប្រិយមិត្តចាប់អារម្មណ៍សូមទំនាក់ទំនងមកកាន់លេខទូរស័ព្ទ : **០១២ ៣៧៧ ៩៦០។/**

**សូមអរគុណ!**

**សារសម្រាប់មិត្តអ្នកអាន!**
បើប្រិយមិត្តចង់មានមតិយោបល់ទៅលើអត្ថបទ មានចម្ងល់ ឬចង់ជូននូវមតិរិះគន់ស្ថាបនា សូមទាក់ទងមកកាន់អាសយដ្ឋានរបស់យើងខ្ញុំ។ យើងខ្ញុំនឹងផ្តល់នូវចម្លើយដោយក្តីរីករាយ។



**សេចក្តីជូនដំណឹង !** *"ផ្សព្វផ្សាយដំណឹងជ្រើសរើសបុគ្គលិកដោយមិនគិតថ្លៃ"* គ្រប់អង្គការក្រុមហ៊ុន និងស្ថាប័នទាំងអស់ដែលមានបំណងចង់ផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ ឬដំណឹងជ្រើសរើសបុគ្គលិកក្នុងតម្លៃទាបបំផុត ហើយចំណេញបានច្រើន សូមទំនាក់ទំនងមកកាន់ការិយាល័យអ្នកនាំសារ ឬអាចទូរស័ព្ទ : ០៩២ ៧៣៧ ២៥៥។ បញ្ជាក់ : គ្រប់ដំណឹងផ្សព្វផ្សាយជ្រើសរើសបុគ្គលិកទាំងអស់ដែលគ្មាន Logo របស់អង្គការក្រុមហ៊ុន ឬស្ថាប័ននានា យើងខ្ញុំនឹងចុះផ្សាយដោយមិនគិតថ្លៃឡើយ។/

November-2008.qxd 10/22/2008 2:16 PM Page 4

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ

### ថ្ងៃអាទិត្យ ទី៣១ ក្នុងរដូវធម្មតា ឆ្នាំ "ក" (ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៨)

*(ម៉ាថាយ ២៣,១-១២)*

ព្រះយេស៊ូបន្ទោសទៅពួកខាងគណៈផារីស៊ី និងពួកធម្មាចារ្យ ដែលជាមនុស្សប្រើប្រាស់សាសនា ដើម្បីបានកិត្តិយស និងកិត្តិនាម ។ ពួកគេពូកែបង្រៀនធម៌វិន័យរបស់លោកម៉ូសេ ប៉ុន្តែគេមិនប្រតិបត្តិ តាមសេចក្តីដែលគេបង្រៀនទេ ។ ពួកគេមានលក្ខណៈពីខាងក្រៅហាក់បីដូចជាមនុស្សសុចរិត តែខាងក្នុង គេមានពុតនិងចិត្តលោភលន់ ។ ចំណែកព្រះយេស៊ូវិញ អ្វីដែលព្រះអង្គមានព្រះបន្ទូល គឺព្រះអង្គប្រតិបត្តិតាម ។ ដូច្នេះ យើងជាគ្រីស្តបរិស័ទត្រូវខិតខំយកចិត្តទុកដាក់ប្រព្រឹត្តតាមជំនឿរបស់ខ្លួនដោយគ្មានពុតត្បុត ។ ជាពិសេស អ្នកដែលទទួលបន្ទុកណែនាំ និងបង្ហាត់អ្នកឯទៀត ដូចជាបូជាចារ្យ អ្នកបួស គ្រូអប់រំជំនឿជាដើម ត្រូវតែអនុវត្តតាមសេចក្តីទាំងប៉ុន្មានដែលខ្លួនបង្ហាត់គេ ។

### ថ្ងៃអាទិត្យ ទី៣២ ថ្ងៃរំឭកបុណ្យឆ្លងព្រះវិហារឡាត្រង់ (ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០០៨)

*(ម៉ាថាយ ២៥,១-១៣)*

ថ្ងៃនេះព្រះសហគមន៍រំឭកបុណ្យឆ្លងព្រះវិហារសន្តយ៉ូហាននៅភ្នំឡាត្រង់ ដែលនោះគឺជាវិសាលព្រះវិហារភូមិភាគទីក្រុងរ៉ូមប្រទេសអ៊ីតាលី ។ លោកអភិបាលនៃព្រះសហគមន៍ទីក្រុងរ៉ូមជាសម្តេចប៉ាប មានបន្ទុកជួយភូមិភាគទាំងអស់នៅក្នុងពិភពលោករួមរស់ជាធ្លុងតែមួយ ។ ហេតុនេះហើយគ្រីស្តបរិស័ទនៃភូមិភាគទាំងមូលរំឭកបុណ្យឆ្លងនេះ និងរាប់ព្រះវិហារឡាត្រង់ទុកជា "ព្រះវិហារទី១" នៅក្នុងចំណោមព្រះវិហារទាំងឡាយ ។ លើសពីនេះទៅទៀត ដូចព្រះវិហារឯទៀតៗដែរ ព្រះវិហារនេះ ជានិមិត្តនៃព្រះសហគមន៍ ។ គ្រីស្តបរិស័ទ គឺប្រៀបបាននឹងថ្មដ៏មានជីវិត ដែលផ្គុំគ្នាឡើងកសាងជាព្រះដំណាក់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ និងព្រះកាយព្រះគ្រីស្ត ។

### ថ្ងៃអាទិត្យ ទី៣៣ និងទី៣៤ ក្នុងរដូវធម្មតា ឆ្នាំ"ក" (ថ្ងៃទី១៦ និងទី២៣ វិច្ឆិកា ឆ្នាំ២០០៨)

ក្នុងជំពូកទី២៤-២៥ នៃកណ្ឌគម្ពីរដំណឹងល្អតាមលោកម៉ាថាយ គឺមានអត្ថបទអំពីព្រះយេស៊ូយាងមកក្នុងអវសានកាលនៃពិភពលោក ។ ថ្ងៃអាទិត្យទី៣៣ និងទី៣៤ នៃរដូវធម្មតា គឺថ្ងៃអាទិត្យចុងក្រោយបង្អស់នៃឆ្នាំ "ក" យើងស្តាប់អត្ថបទ នាំឱ្យយើងរិះគិតអំពីភារកិច្ចយើង នៅពេលរង់ចាំព្រះអង្គយាងមក ។ ក្នុងប្រស្នាអំពីប្រាក់ណែន (ម៉ាថាយ ២៥,១៤-៣០) បុរសដែលចេញដំណើរទៅស្រុកឆ្ងាយ គឺព្រះយេស៊ូដែលយាងទៅស្ថានបរមសុខ ។ ប្រាក់មួយណែនគឺស្មើនឹង ៣៤គីឡូក្រាមប្រាក់ ដែលជានិមិត្តរូបរបស់អំណោយទាន និងទេពកោសល្យដែលព្រះជាម្ចាស់ប្រទានឱ្យយើងរាល់គ្នាដើម្បីបម្រើព្រះអង្គក្នុងលោកនេះ ។
ក្នុងអត្ថបទអំពីការកាត់ទោសនៅគ្រាចុងក្រោយបង្អស់ (ម៉ាថាយ ២៥,៣១-៤៦) យើងយល់អំពីរបៀបណា ដែលព្រះជាម្ចាស់នឹងវិនិច្ឆ័យមនុស្សលោក? ព្រះអង្គនឹងញែកមនុស្សទៅតាមសេចក្តីស្រឡាញ់ដែលមនុស្សបានបង្ហាញចំពោះជនក្រីក្រកំសត់ទុគ៌ត ។ យើងស្តាប់អត្ថបទនេះនៅថ្ងៃបុណ្យ គោរពព្រះគ្រីស្តក្នុងឋានៈជាព្រះមហាក្សត្រនៃពិភពលោក ។ ដូច្នេះហើយ យើងយល់ថា ព្រះយេស៊ូជាព្រះមហាក្សត្រមែន ក៏ប៉ុន្តែខុសពីស្តេចលោកីយ៍ ដែលរក្សាទុកអំណាចរបស់ខ្លួននិងរកប្រយោជន៍ផ្ទាល់ខ្លួន ។ ព្រះយេស៊ូជាគង្វាលដ៏សប្បុរសដែលរវីរវល់ និងប្រជារាស្ត្រទាំងអស់ ជាពិសេសអ្នកឥតមានទីពឹង ។

### ថ្ងៃអាទិត្យ ទី១ ក្នុងរដូវរង់ចាំ ឆ្នាំ "ខ" (ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៨)

*(ម៉ាថាយ ២៥,៣១-៤៦)*

ថ្ងៃអាទិត្យនេះ ជាថ្ងៃចូលរដូវរង់ចាំឆ្នាំ "ខ" ដែលមានរយៈពេលបួនអាទិត្យ គឺ រហូតដល់បុណ្យណូអែល ។ ព្រះសហគមន៍ដាស់តឿនគ្រីស្តបរិស័ទឱ្យរៀបចំចិត្តគំនិតដើម្បីទទួលព្រះគ្រីស្ត ដែលកំពុងយាងមក ។ ថ្ងៃអាទិត្យនេះ ពាក្យសំខាន់ជាងគេ គឺ "ចូរប្រុងស្មារតី!" ។ អ្នកបម្រើដែលកំពុងតែដេកលក់ ជាគ្រីស្តបរិស័ទដែលលែងចូលរួមពិធីបុណ្យ និងលែងស្វែងរកអំពីអត្ថន័យពីជំនឿរបស់ខ្លួន លែងចែករំលែកពេលវេលា ឬធ្វើទានជួយអ្នកដទៃទៀត ។ ក្នុងរដូវរង់ចាំ គួរឱ្យយើងភ្ញាក់ឡើងដោយពិចារណា និងគិតថា ព្រះអម្ចាស់សព្វព្រះហឫទ័យអ្វីខ្លះដែលយើងអាចធ្វើដើម្បីរៀបចំបុណ្យព្រះយេស៊ូប្រសូតយ៉ាងសមរម្យ ។

*(អ្នកនាំសារ ខែវិច្ឆិកា ២០០៨ - អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ / លោកបូជាចារ្យ វ៉ាំងសង់ សេនីយ៍អាល់)*

## យើងអាន


Photo: DR

### ប្រវត្តិសន្តប៉ូល

ប្អូនៗបានស្គាល់រួចមកហើយ អំពីរបៀបដែលគ្រីស្តទូតប៉ូល កែប្រែចិត្តគំនិត និងអំពីរបៀបដែលព្រះយេស៊ូត្រាស់ហៅគ្រីស្តទូតប៉ូល។ យើងដឹងទៀតថា លោកជាគ្រីស្តទូតម្នាក់ក្នុងចំណោមគ្រីស្តទូតឯទៀតៗ។
លោកកែប្រែចិត្តដោយសារព្រះយេស៊ូត្រាស់ហៅ ពេលលោកកំពុងធ្វើដំណើរទៅកំចាត់គ្រីស្តបរិស័ទនៅក្រុងដាម៉ាស់។
លោកទទួលអគ្គសញ្ញាជ្រមុជទឹក ជាមួយលោកអាណានីយ៉ា។ ការរាប់លោកប៉ូលដែលជាអ្នកបៀតបៀនគ្រីស្តបរិស័ទពីមុនមក ជាគ្រីស្តទូតនោះ មានអ្នកជាច្រើនមិនសូវពេញចិត្តឡើយ។ គ្រីស្តទូតប៉ូលបានចេញទៅប្រកាសដំណឹងល្អគ្រប់ទីកន្លែងក្នុងពិភពលោកទាំងមូល។ ក្រោយពីព្រះវិញ្ញាណជ្រើសយកគ្រីស្តទូតប៉ូល និងលោកបាណាបាសឱ្យចេញទៅប្រកាសដំណឹងល្អ។ លោកទាំងពីរបានធ្វើដំណើរទៅក្រុងអន់ទីយ៉ូក។ លោកបានជួបបងប្អូននៅក្នុងព្រះសហគមន៍ អធិដ្ឋានរួម និងអានព្រះគម្ពីរ។ លោកអប់រំគ្រីស្តបរិស័ទឱ្យកាន់តែច្បាស់ថែមទៀត។ នៅកោះគីប្រុស លោកបានប្តូរឈ្មោះពី "សូល" តាមហេប្រឺ ទៅជាឈ្មោះរ៉ូម៉ាំងវិញ គឺ "ប៉ូល"។ គ្រីស្តទូតប៉ូលធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ ឆ្លងកាត់ឧបសគ្គរាប់មិនអស់ ដើម្បីតែដំណឹងល្អអំពីព្រះគ្រីស្ត។ លោកត្រូវតែចាប់ជាញឹកញាប់ និងទទួលរងនូវព្យុះរាប់មិនអស់លើផ្ទៃសមុទ្រ។
សម័យនោះ ព្រះសហគមន៍ក៏មានជួបនូវបញ្ហាដូចយើងសព្វថ្ងៃនេះដែរ។ គ្រីស្តទូតប៉ូលបានសរសេរលិខិតផ្សេងៗទៅលើកទឹកចិត្តអប់រំគ្រីស្តបរិស័ទតាមព្រះសហគមន៍ទាំងប៉ុន្មានដែលលោកបានទៅ។ លោកណែនាំឱ្យគ្រីស្តបរិស័ទដើរតាមមាគ៌ារបស់ព្រះជាម្ចាស់ជានិច្ច ទាំងការជួបជុំលើកតម្កើងព្រះជាម្ចាស់ និងការជួបជុំស្តាប់ព្រះបន្ទូល។ ទោះបីលោកបានជាប់ឃុំឃាំងជាច្រើនលើកច្រើនសា លោកបានយកពេលមួយចំនួនអរព្រះគុណព្រះជាម្ចាស់ និងសរសេរសំបុត្រទៅសួរសុខទុក្ខបងប្អូនតាមព្រះសហគមន៍នានា។

លី សុវណ្ណា



# ព័ត៌មានទូទៅ


Photo: R. Dina

### តានតឹង៣ខែ ខ្មែរ-សៀម ព្រលះគ្នា ទីបំផុត

ភាពតានតឹងនៃការប្រឈមមុខគ្នាដោយអាវុធនៃកងទ័ពកម្ពុជា និងសៀមក្នុងជម្លោះព្រំដែននៃតំបន់ប្រាសាទព្រះវិហារ ឈានដល់ការបាញ់ប្រហារគ្នា ជាលើកទី២ កាលពីថ្ងៃទី១៥តុលានេះ ដែលរយៈពេលបី ខែគត់ (១៥ កក្កដា-១៥ តុលា) ដែលធ្វើឱ្យកងទ័ពកម្ពុជា ចំនួន ៣នាក់ ពលីជីវិត និងរបួស ២នាក់ ។ តាមប្រភពក្រៅផ្លូវការ ទ័ពសៀម ១៥នាក់ ស្លាប់ និងរបួសមួយចំនួន ។ ការផ្ទុះអាវុធនេះបានកើតឡើងជាថ្មីក្រោយពីការប៉ុនប៉ងមិនបានសម្រេចរបស់សៀមក្នុងការដណ្តើមយកវាលឥន្រ្ទី ដែលជាទឹកដីរបស់ខ្មែរចម្ងាយ ២៥០០ម ខាងលិចប្រាសាទព្រះវិហារ កាលពីថ្ងៃទី៦ តុលា ដោយមានការផ្ទុះអាវុធជាង ១០នាទីម្តងរួចទៅហើយនោះ ។ ការប៉ះពេលនោះ មានទាហានខ្មែរម្នាក់របួសស្រាល និងថៃ ២នាក់រងរបួសធ្ងន់ ។ នៅល្ងាចថ្ងៃទី១៥ តុលា លោកឧបនាយករដ្ឋមន្ត្រី ហោ ណាំហុងបានប្រាប់ក្នុងសន្និសីទកាសែតថា ទ័ពថៃបានវាយប្រហារដោយ អាវុធមកលើកងទ័ពកម្ពុជា ត្រង់៣ ចំនុច គឺនៅវត្តកែវសិក្ខាគីរីស្វារៈ វាលឥន្រ្ទី និងភ្នំទ្រព្យ ហើយទ័ពកម្ពុជាបានឆ្លើយតបក្នុងសិទ្ធិការពារខ្លួន ។

### សន្តិសុខស្បៀង : ធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់ប្រាក់ចំនួន ៣៥ លានដុល្លារដល់កម្ពុជា

ធនាគារអភិវឌ្ឍន៍អាស៊ី បានផ្តល់ជំនួយស្បៀងអាហារសង្គ្រោះបន្ទាន់ដល់គ្រួសារខ្មែរក្រីក្របំផុត កន្លះលាននាក់នៅខេត្តជុំវិញបឹងទន្លេសាប បន្ទាយមានជ័យ ឧត្តរមានជ័យ និងសង្កាត់ក្រីក្រចំនួនបី ក្នុងក្រុងភ្នំពេញ ខណៈពេលដែលពួកគេកំពុងប្រឈមនឹងការឡើងថ្លៃនៃម្ហូបអាហារ និងប្រេងឥន្ធនៈ ។គម្រោងជំនួយសង្គ្រោះបន្ទាន់នេះ មានរយៈពេលបីឆ្នាំ គឺ ២០០៨-២០១១ ។ រដ្ឋាភិបាលកម្ពុជា បានចូលរួមថវិកាបដិភាគ ចំនួន ៥លានដុល្លារ ដែលធ្វើឱ្យទឹកប្រាក់គម្រោងកើនដល់ ៤០លានដុល្លារ ។ លោកអាជុន ហ្គូសវ៉ាមី នាយកធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅកម្ពុជា និយាយថា គម្រោងនេះនឹងផ្តល់ ដល់អ្នកក្រីក្រ ដែលគ្មានដីអ្នកដែលរកមួយថ្ងៃសម្រាប់មួយថ្ងៃ កសិករដែលមានដីតិច និងជនក្រីក្រដែលរស់នៅក្នុងតំបន់អាណាធិបតេយ្យឯក្រុងភ្នំពេញ ។ ជំនួយនេះមានអង្ករ ស្រូវពូជ និងជីកសិកម្ម ។

### ហោ ណាំហុង : ការចរចាកំណត់ព្រំដែនសមុទ្រកម្ពុជា-វៀតណាម គួរចាប់ផ្តើម

លោកហោ ណាំហុង បានស្នើសុំឱ្យគណៈកម្មាធិការព្រំដែនកម្ពុជា-វៀតណាម ផ្តើមកិច្ចចរចាដើម្បីកំណត់ព្រំដែន សមុទ្រនៃប្រទេសជិតខាងទាំងពីរដោយស្វែងរកកាលបរិច្ឆេទដ៏សមស្របណាមួយដើម្បីឱ្យមានការជួបគ្នារវាងតំណាងប្រទេសទាំងពីរ ។ យោងតាមសេចក្តីថ្លែងការរបស់ក្រសួងការបរទេសកម្ពុជាដែលចែកផ្សាយនៅដើមខែតុលា ការស្នើសុំនេះ បានត្រូវធ្វើឡើងនៅក្នុងកិច្ចប្រជុំលើកទី១០ នៃគណៈកម្មាធិការចម្រុះកម្ពុជា-វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស ដែលប្រព្រឹត្ត ទៅនៅថ្ងៃទី៦-៧ តុលា នៅប្រទេសវៀតណាម ។

រស់ ឌីណា

### សមាគមព្រះគម្ពីរកម្ពុជា ធ្វើពិធីបុណ្យខួប ៤០ឆ្នាំ


Photo: L. Sovanna

គ្រីស្តបរិស័ទគ្រប់និកាយប្រមាណ ២០០នាក់ បានមកជួបជុំអធិដ្ឋាន អរគុណព្រះជាម្ចាស់ ក្នុងពិធីខួប ៤០ឆ្នាំ នៃសមាគមព្រះគម្ពីរកម្ពុជា(SBC) ។ ពិធីនេះ គឺបានប្រារព្ធធ្វើនៅថ្ងៃទី១០ តុលាកន្លងទៅ នៅឯមជ្ឈមណ្ឌលព័ន្ធកិច្ចឯកភាពគ្រីស្តបរិស័ទ ផ្ទះលេខ ១៩-២១ ផ្លូវ៣៣០ សង្កាត់បឹងកេងកង៣ ក្រុងភ្នំពេញ ។
អ្នកស្រីទ្រឿង លាភ រំលឹក នាយកផ្នែកបោះពុម្ពផ្សាយនៃសមាគមព្រះគម្ពីរកម្ពុជា បានធ្វើរបាយការណ៍រយៈ ១៥ឆ្នាំ ចុងក្រោយ បន្ទាប់ពីការចាប់កំណើតឡើងវិញរបស់សមាគមគម្ពីរក្រោយពីសង្គ្រាម ។ ចំណែកលោកគ្រូសុខ ញឹប អរុណ ជាទីប្រឹក្សាសមាគមព្រះគម្ពីរសកល ទទួលបន្ទុកតំបន់អាស៊ីប៉ាស៊ីហ្វិច មានប្រសាសន៍ថា SBC បង្កើតឡើងនៅឆ្នាំ ១៩៦៨ នៅកម្ពុជា ។ នៅឆ្នាំ១៩៧៥ គណៈកម្មការមួយ មានសមាជិក ៥នាក់ មកពីនិកាយផ្សេងៗ បានបញ្ចប់ជំហានដំបូង នូវព្រះគម្ពីរដំណឹងល្អ ។ ប៉ុន្តែឆ្នាំនោះ SBC ត្រូវបិទទ្វារ ។ សមាជិកម្នាក់បានចាកចេញពីប្រទេសដោយនាំយកព្រះគម្ពីរតាមលោកម៉ាថាយ៥ជំពូកដែលបកប្រែជាខ្មែររួច ។ សមាជិកឯទៀតត្រូវខ្មែរក្រហមសម្លាប់ទាំងអស់ ។

### រិះគិតពីការត្រាស់ហៅ ត្រូវជួយគាំទ្រ លើកទឹកចិត្ត និងអធិដ្ឋាន


Photo: L. Sovanna

នេះគឺជាពាក្យសំណូមពរយ៉ាងទទូចពីនិស្សិតទេវវិទ្យាល័យកម្ពុជាក្នុងឱកាសបើកបវេសនកាលថ្មីរបស់ខ្លួន កាលពីថ្ងៃទី ១០ខែតុលា ។
លោកមួង រស់តំណាងនិស្សិតទេវវិទ្យាល័យថ្លែងថា: "ទេវវិទ្យាល័យមានសារៈសំខាន់ សម្រាប់ព្រះសហគមន៍កាតូលិក ក្នុងការអប់រំយុវជន" ។ លោកបន្តថា ទទួលការអប់រំជាបូជាចារ្យ គឺមានការពិបាកច្រើន ។ យើងរៀនរស់នៅរួមគ្នាជាបងប្អូន ស្វែងយល់ជីវិតខាងវិញ្ញាណ ដោយស្តាប់ព្រះបន្ទូល និងការអធិដ្ឋាន បម្រើព្រះសហគមន៍ និងបងប្អូន ។ រាល់សកម្មភាពទាំងនេះនិស្សិតត្រូវការជួយគាំទ្រលើកទឹកចិត្ត និងជួយអធិដ្ឋានផងដែរ ។
លោកអេមីល ដេតម្ប អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញមានប្រសាសន៍ថា : "ការជួយគាំទ្រគ្នាជាការសំខាន់ និងជាបេសកកម្មរបស់យើងម្នាក់ៗ" ។ លោកសង្កត់ធ្ងន់ថា: "ការជួបជុំថ្ងៃនេះដើម្បីជួយគាំទ្រនិស្សិតទេវវិទ្យាល័យ ដែលកំពុងរិះគិតពីការត្រាស់ហៅរបស់ព្រះជាម្ចាស់ និងក្លាយជាសាក្សីអំពីសេចក្តីស្រឡាញ់របស់ព្រះយេស៊ូ ។

លី សុវណ្ណា

November-2008.qxd 10/22/2008 2:16 PM Page 6



# សិក្ខាសាលាស្តីអំពីការទប់ស្កាត់គ្រោះមហន្តរាយ

**តន**

អង្គការការីតាសកម្ពុជា បានរៀបចំនូវសិក្ខាសាលាមួយមានរយៈពេល ៣ថ្ងៃពីការត្រៀមបង្ការគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋានដែលមានសិក្ខា-កាមចូលរួមប្រមាណជា២៩នាក់ ដែលជាសមាជិកនៃអង្គការការីតាសទាំង៨ខេត្ត-ក្រុង។ អង្គសិក្ខា-សាលានេះ បានធ្វើឡើង នៅការិយាល័យកណ្តាលរបស់អង្គការការីតាស ក្រុងភ្នំពេញ។ សិក្ខាសាលាបានប្រព្រឹត្តទៅពីថ្ងៃទី១៥-១៧ តុលាកន្លងទៅ។ ជាមួយនិងការពន្យល់ពីអ្នកឯកទេសមកពីប្រទេសឥណ្ឌា វគ្គសិក្សានេះជាការបំពេញចំណេះដឹងបន្ថែមដល់បុគ្គលិកការីតាស កម្ពុជា ឱ្យកាន់តែទទួលបាននូវជំនាញ ដើម្បីបង្ហាត់បង្រៀនប្រជាជន នៅតាមសហគមន៍នានា អំពីការបង្ការនូវគ្រោះមហន្តរាយដែលមិនអាចដឹងទុកជាមុន មានជាអាទិ៍ខ្យល់ព្យុះទឹកជំនន់ និងគ្រោះរាំងស្ងួត-ល-។

លោកនុតសំអុល ប្រធានអង្គការការីតាសបានគូសបញ្ជាក់ថា ទិសដៅសំខាន់ ក្នុងអង្គសិក្ខាសាលានេះ គឺដើម្បីផ្លាស់គំនិតរបស់ប្រជាជនតាមសហគមន៍ឱ្យចេះរិះរកនូវមធ្យោបាយ និងចេះប្រើប្រាស់ធនធានដែលមានស្រាប់នៅតាមទីកន្លែង ដែលពួកគាត់រស់នៅ ទោះបីជាជួបគ្រោះមហន្តរាយជាជាងការរំពឹងតែជំនួយពីអ្នកដទៃនៅពេលជួបបញ្ហា។



Photo : L. Samphors

សិក្ខាកាមប្រជុំពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់ដើម្បីពង្រីកចំណេះដឹងមួយយ៉ាងសំខាន់ក្នុងការជួយជនរងគ្រោះពេលជួបគ្រោះមហន្តរាយ។

# គម្រោងអប់រំជំនឿយុវជននៅភូមិភាគភ្នំពេញ

ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៨ ដល់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ជាឆ្នាំរបស់សន្តប៉ូលហើយគ្រីស្តបរិស័ទលើពិភពលោក បានធ្វើការគិតពិចារណារួមគ្នានូវលិខិតរបស់សន្តប៉ូល ហើយក៏ដូចជីវិតរបស់គាត់ដែរ។ អាស្រ័យហេតុនេះការិយាល័យយុវជនភូមិភាគភ្នំពេញបានរៀបចំកម្មវិធីសម្រាប់យុវជនយុវនារីភូមិភាគភ្នំពេញដើម្បីធ្វើការគិតរួមគ្នាដែរ ដែលផ្តោតលើចំណុច ២សំខាន់ៗ :

I-វគ្គបណ្តុះបណ្តាលពីការឆ្លុះបញ្ចាំងខ្លួនឯង និងអំពីបេសកកម្មរបស់យុវជនក្នុងព្រះសហគមន៍ (សន្តប៉ូល)

II-វគ្គបណ្តុះបណ្តាលអំពីការប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ (សន្តប៉ូល)

ក្នុងវគ្គបណ្តុះបណ្តាលទាំងពីរខាងលើនេះ យើងមានគោលបំណងដូចជា :

១-ធ្វើឱ្យយុវជនយុវនារីស្គាល់ខ្លួនឯងថាជាអ្នកណា និងធ្វើឱ្យយុវជនយុវនារីពង្រឹងសមត្ថភាពផ្ទាល់ខ្លួន។

២-ជំរុញឱ្យយុវជនយុវនារីចូលរួមបម្រើព្រះសហ-គមន៍ និងឱ្យយុវជនយុវនារីទទួលស្គាល់ព្រះសហគមន៍មានសារៈសំខាន់ (ដូចលោកប៉ូលបានធ្វើ)។

៣-ឱ្យយុវជនយុវនារីហ៊ានប្រកាសព្រះបន្ទូលដំណឹងល្អរបស់ព្រះជាម្ចាស់ និងឱ្យយុវជនយុវនារី យកព្រះជាម្ចាស់ជាបន្ទាល់សម្រាប់ជីវិតរបស់ពួកគេ។

ភ្នំពេញ, ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៨

ផុន សុផល

# JSC ផ្តល់អគារមត្តេយ្យសាលាជូនដល់ឃុំបឹងធំ

អគារមត្តេយ្យសាលា១ខ្នង ២បន្ទប់ ដែលជាអំណោយពីអង្គការជេអេសស៊ី ផ្តល់ជូនប្រជាពលរដ្ឋ ឃុំបឹងធំ ស្រុកអង្គស្នួលខេត្តកណ្តាល ត្រូវដាក់សម្ពោធឱ្យប្រើប្រាស់កាលពីថ្ងៃទី១០ តុលា ឆ្នាំ២០០៨កន្លងទៅនេះ។ ពិធីសម្ពោធនោះ មានការអញ្ជើញចូលរួមពីលោកបូជាចារ្យហ្គេ ប្រ៊ីអែល ជាប្រតិភូនៃអង្គការជេអេសស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា បងស្រីអាត នាយិកាប្រតិបត្តិគម្រោងអភិវឌ្ឍន៍ សហគមន៍ស្រុកអង្គស្នួល រួមនិងអាជ្ញាធរមូលដ្ឋាន លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋយ៉ាងច្រើនកុះករ។ ថ្លែងក្នុងពិធី លោកបូជាចារ្យហ្គេ ប្រ៊ីអែល បានឱ្យដឹងថា អគារមត្តេយ្យសាលាដែលត្រូវបានដាក់សម្ពោធនាពេលនេះ គឺជាអំណោយដ៏តូចតាចរបស់អង្គការជេអេសស៊ីដែលផ្តល់ជូនសាលាបឋមសិក្សាបឹងធំ។ កន្លងមកអង្គការជេអេសស៊ី បានយកចិត្តទុកដាក់ជួយលើវិស័យអប់រំ ដែលជាវិស័យមួយដ៏សំខាន់ក្នុងការជួយអភិវឌ្ឍប្រទេសជាតិ។ មត្តេយ្យសាលានេះ គឺជាថ្នាលជួយបណ្តុះបណ្តាលកូនក្មេងៗឱ្យក្លាយទៅជាពន្លកថ្មីដែលជាក្តីសង្ឃឹមរបស់សង្គមជាតិយើង។

ឡុង សម្ផស្ស

## ក្រុមសន្តអន់ត្រេ រៀបចំកម្មវិធីសម្រាប់មនុស្សចាស់

កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៨ ក្រុមសន្តអន់ត្រេ បានប្រារព្ធធ្វើពិធីជប់លៀង ឱ្យមនុស្សចាស់ អាយុ៦០ឆ្នាំឡើងចំនួន២០នាក់ (យាយ ១៧នាក់ និងតា ៣នាក់) នៅព្រះសហគមន៍កំពង់ចាម។ ពួកគាត់មកពីភូមិរលៀកភូមិ វត្តអង្គរ ចំការខ្ពប ឆ្នាអើត និងភូមិបឹងកុក។ គោលបំណងរបស់ក្រុម ធ្វើពិធីជប់លៀងនេះ គឺទី១ អរគុណចាស់ៗបានធ្វើកិច្ចការច្រើនដល់សង្គម។ ទី២ គឺឱ្យពួកគាត់ជួបជុំគ្នាលេងរាំ និងពិសាអាហារទាំងអស់គ្នា ព្រោះពួកគាត់ជាអ្នកក្រីក្រ និងខ្លះនៅឯកោ។ ក្នុងកម្មវិធី មានលេងល្បែងកំសាន្ត របាំ ពិធីកាត់នំរួមជាមួយគ្នា និងពិសាអាហារ។ លោកតាលោកយាយសប្បាយរីករាយដែលក្រុមសន្តអន់ត្រេបានលើកទឹកចិត្តពួកគាត់ឱ្យមើលឃើញអំពីតម្លៃនៃជីវិត។ នៅចុងបញ្ចប់នៃកម្មវិធី មានចែកអំណោយជា (អង្ករ ក្រម៉ា និងស្ករស) ខ្លះៗ ដល់ពួកគាត់។

**កំពង់ចាម**



Photo : DR





# សកម្មភាព ៥ឆ្នាំ ដំបូង នៃវិទ្យាល័យសន្តហ្វ្រង់ស្វ័រ

**លី សុវណ្ណា**

វិទ្យាល័យចំណេះទូទៅ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សន្តហ្វ្រង់ស័រជាវិទ្យាល័យចំណេះទូទៅរបស់ព្រះសហគមន៍កាតូលិកតែ១គត់ នៅប្រទេសកម្ពុជា។ ការអប់រំចំណេះទូទៅ សម្រាប់យុវជន-នារី កុមារកុមារីជាគោលដៅអាទិភាពចម្បងគេ ក្នុងចំណោមវិស័យនានារបស់ព្រះសហគមន៍កាតូលិកដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍ធនធានមនុស្សស្របតាមយុទ្ធ-សាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។

វិទ្យាល័យសន្តហ្វ្រង់ស័រ បានផុសឡើងនៅកណ្តាលវាលស្រែ នៃព្រះសហគមន៍កាតូលិក នៅភូមិចំការទៀង ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ។

លោកបូជាចារ្យ អូលីវីយេ អ្នកសម្របសម្រួលនៃវិទ្យាល័យ បានបញ្ជាក់អំពីគោលដៅនៃការបង្កើតវិទ្យាល័យនេះថា ដើម្បីអប់រំបណ្តុះបណ្តាលសិស្ស-និស្សិត ឱ្យក្លាយទៅជាមនុស្សឈ្លាសវៃ ប៉ិនប្រសប់ សុចរិត ស្អាតស្អំ គោរពអ្នកដទៃ មានសេរីភាព និងទទួលខុសត្រូវ ដើម្បីឱ្យពួកគេកសាងជីវិតរស់នៅក្នុងសេចក្តីថ្លៃថ្នូរ និងសុខដុមរមនា។

វិទ្យាល័យសន្តហ្វ្រង់ស័រ គឺបានកសាងឡើងនៅឆ្នាំ២០០៣ និងបើកទទួលសិស្សវិទ្យាល័យថ្នាក់ទី១០ ចំនួន៣២នាក់ និងក៏បើកថ្នាក់បង្រៀនគួរសម្រាប់សិស្សថ្នាក់ទី១២។ នៅឆ្នាំសិក្សា ២០០៤-២០០៥ ទទួលសិស្សចំនួន ៣២នាក់ បន្ថែម។ នៅឆ្នាំដដែលនេះវិទ្យាល័យចំណេះទូទៅ បានបន្ថែមមុខវិជ្ជាជីវៈលេខាធិការនិងជំនាញកសិកម្ម។ ជំនាញខាងកសិ-កម្ម មានការជួយគាំទ្រពីសកលវិទ្យាល័យភូមិន្ទនៃកសិកម្មចំការដូង។ នៅឆ្នាំសិក្សា២០០៥-២០០៦ ទទួលសិស្សថ្មី៣៦នាក់ថែមទៀត។ នៅឆ្នាំ២០០៦ វិទ្យាល័យ ក៏បានអភិវឌ្ឍខ្លួនទៅជាវិទ្យាស្ថានកសិ-កម្មសន្តហ្វ្រង់ស័រ ដែលនិស្សិតបញ្ចប់នូវការសិក្សាអាចទទួលបានវិញ្ញាបនបត្រជាន់ខ្ពស់។ វិទ្យាស្ថានបានធ្វើកិច្ចសហប្រតិបត្តិការ យ៉ាងជិតស្និទ្ធ ជាមួយសកលវិទ្យាល័យចំការដូង។ នៅឆ្នាំសិក្សា២០០៦-២០០៧ ការប្រលងមធ្យមសិក្សាទុតិយភូមិ សិស្សថ្នាក់ទី១២ ប្រលងជាប់ ១០០%។ លោកបូជាចារ្យអូលីវីយេបន្តថា សិស្សវិទ្យាល័សន្តហ្វ្រង់ស័រ មានសំណាង ព្រោះអាចប្រើបណ្តាញអ៊ីនធើណែតដែលទទួលការឧបត្ថម្ភអំពីសហគមន៍អឺរ៉ុប។ លោកបន្តថា ឆ្នាំ២០០៨-២០០៩ គឺមានកំណែទម្រង់បន្ថែមដោយបើកថ្នាក់អនុវិទ្យាល័យ ដែលមានមុខជំនាញពីរឱ្យជ្រើសរើសគឺលេខាធិការ និងកសិកម្ម។ ក្រៅពីនេះ មានបន្ថែមសិក្សាភាសាអង់គ្លេស បារាំង កូរ៉េ កីឡាទំនើប និងកុំព្យូទ័រ។ សិស្សនឹងអាចទទួលការអប់រំទាំងពីរព្រមគ្នា គឺចំណេះទូទៅ និងជំនាញ។

## ប្រវត្តិវិទ្យាល័យសន្តហ្វ្រង់ស្វ័រ

**វិទ្យាល័យចំណេះទូទៅ និងបណ្តុះបណ្តាលវិជ្ជាជីវៈសន្តហ្វ្រង់ស្វ័រ ភូមិចំការទៀង បង្កើតឡើងដោយលោកបូជាចារ្យអូលីវីយេ។ នៅ២០០២ បង្កើតសាលាមត្តេយ្យ។ ឆ្នាំ២០០៣ កសាងវិទ្យាល័យសន្តហ្វ្រង់ស័រ ដែលមានការគាំទ្រពីអង្គការកុមារមេត្តា ហើយបើកសម្ពោធដោយឯកឧត្តមបណ្ឌិតចាន់ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលោកអគ្គរាជទូតសម្តេចប៉ាបប្រចាំនៅកម្ពុជា។ ឆ្នាំ២០០៦ អភិវឌ្ឍន៍ជាវិទ្យាស្ថានបច្ចេកទេសសន្តហ្វ្រងស្វ័រថ្នាក់បរិញ្ញាបត្ររង។ ឆ្នាំ២០០៨ បង្កើតថ្នាក់អនុវិទ្យាល័យ។ ឆ្នាំ២០០៩ នឹងបើកថ្នាក់ឧត្តមសិក្សាព័ត៌មានវិទ្យា និងកសិកម្ម។ សាលានេះក៏បានធ្វើទំនាក់ទំនងជាមួយវិទ្យាល័យ និងមហាវិទ្យាល័យនានានៅក្រៅប្រទេស ដូចជាបារាំង ជប៉ុន និងសិង្ហបុរី ព្រមទាំងផ្លាស់ប្តូរដំណើរទស្សនកិច្ចរបស់សិស្សទៅវិញទៅមកផងដែររវាងប្រទេសនីមួយៗ។**



វិទ្យាល័យសន្តហ្វ្រង់ស័របើកសម្ពោធអគារបណ្ណាល័យបន្ថែមកាលឆ្នាំ២០០៦ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតចាន់ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលោកអគ្គរាជទូតសម្តេចប៉ាប ប្រចាំនៅកម្ពុជា

Photo : L. Sovanna

November-2008.qxd 10/22/2008 2:16 PM Page 8



# “រួបរួមគ្នា” ទស្សនាវដ្ដីដើម្បីសុខភាពជនងាយរងគ្រោះ

ជាត សំភី


ទស្សនាវដ្ដីរួបរួមគ្នា
Photos : P. Samphy

សព្វថ្ងៃនេះ ការអភិវឌ្ឍន៍ប្រទេសជាតិមួយអាចធ្វើទៅបាន ទាល់តែប្រជាជននោះមានចំណេះដឹងទូលំទូលាយ ។ ឆ្លងតាមរយៈនេះទើបអង្គការស៊ីដ(ការចែករំលែកបទពិសោធន៍ដើម្បីសម្របទៅតាមការអភិវឌ្ឍន៍" បានបង្កើតទស្សនាវដ្ដីប្រជាប្រិយ មួយហៅថា "រួបរួមគ្នា" ដែលបង្ហាញជូនដល់អ្នកដែលរស់នៅជាមួយនិងជំងឺអេដស៍ អ្នកជំងឺអេសដី និងអ្នកដែលងាយរងគ្រោះនៅកម្ពុជា ។ទស្សនាវដ្ដីនេះមានអត្ថបទដែលទាក់ទងនិងជំងឺអេដស៍ សុខភាពទូទៅ ការធ្វើអនាម័យ និងបង្ការរោគផ្សេងៗ-ល-ដែលផ្ដល់ដោយអង្គការដៃគូ ឬមានការបកស្រាយដោយគ្រូពេទ្យឯកទេសជំនាញៗ ។

ដោយមានការិយាល័យស្ថិតក្នុងមន្ទីរពេទ្យ កុសមៈហៅ "ពេទ្យលោកសង្ឃ" ទស្សនាវដ្ដី "រួបរួមគ្នា" ក៏បានចេញផ្សាយបីលេខ រៀងរាល់បីខែម្ដង ។ លេខទីមួយចេញផ្សាយចំនួន ១៥០០០ច្បាប់ លេខទីពីរ ១៥០០០ច្បាប់ និងលេខទីបី ២០០០០ច្បាប់ ។ ការបង្កើនចំនួននេះ គឺក្នុងគោលដៅឱ្យអ្នកផ្ទុក អ្នកជំងឺអេដស៍ និងអ្នកងាយរងគ្រោះបានអានគ្រប់ៗគ្នា ។

កញ្ញាគីម សុធា អ្នកជំនួយការនៃប្រធានគម្រោងទស្សនាវដ្ដីបញ្ជាក់ថា យើងចែកផ្សាយតាមអង្គការក្រៅរដ្ឋាភិបាលនានាដើម្បីចែកបន្តទៅដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ។ ទីពីរ យើងក៏ផ្ដល់ទៅឱ្យមជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ក្រសួងសុខាភិបាល ដើម្បីធ្វើការចែកបន្តទៅកាន់ មណ្ឌលកម្មវិធីអេដស៍ នៅគ្រប់ខេត្តក្រុងទូទាំងប្រទេស ។

ដោយរំឭកពីគំនិតនៃការបង្កើតទស្សនាវដ្ដី គ្រាដំបូងលោក មីឆែល ហ៊ីហ្គ ជាអ្នកសម្របសម្រួលកម្មវិធីមានប្រសាសន៍ថា : "យើងសង្កេតឃើញថា វាពិតជាមានតម្រូវការនៅក្នុងប្រទេសកម្ពុជា លើវិស័យទំនាក់ទំនង ការអប់រំ និងការពន្យល់អំពីបំនិនជីវិតសម្រាប់ប្រជាជនដែលងាយរងគ្រោះ ។"

តាមការចេញផ្សាយ បានពីរលេខកន្លងមក លោកហ៊ីហ្គ អះអាងថា យើងទទួលបាននូវលទ្ធផលដ៏ល្អដោយមានការពេញចិត្តពីមិត្តអ្នកអាន និងអង្គការដៃគូ ដែលយល់ថាមានប្រយោជន៍ដល់ពួកគេ ។

សព្វថ្ងៃនេះ គម្រោងបានទទួលការឧបត្ថម្ភពីស្ថាប័ននានា ដូចជាអង្គការគ្រូពេទ្យពិភពលោក ស្ថានទូតបារាំង ជប៉ុន និងអង្គការដៃគូជាច្រើនទៀត ។

# ជា ប៊ុនធឿន : "គោលដៅគឺឱ្យចំណេញដល់អ្នកអានអត្ថបទ"

ជាអ្នកយកព័ត៌មានឱ្យទស្សនាវដ្ដី"រួបរួមគ្នា" លោក ជា ប៊ុនធឿន វ័យ ២៨ឆ្នាំ អ្នកកាសែតអាជីពមួយរូប ។ លោកគឺជាអតីតនិស្សិតនៅដេប៉ាតឺម៉ង់ភាសាបារាំង នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ និងមានជំនាញឯកទេសជាអ្នកសរសេរកាសែត ។

ក្នុងសំដីមួយៗ ហាក់ដូចជាកំពុងសញ្ជឹងគិត លោកបានរំឭក អំពីការចងចាំខ្លះ មុននឹងចាប់យកជំនាញនេះថា គឺដោយសារលោកច្រើនចង់ដឹង ចង់ឮ និងមានការជឿងឆ្ងល់ច្រើនតាមនិស្ស័យពីធម្មជាតិ" ។

បន្ទាប់ពីបញ្ចប់ការសិក្សានៅឆ្នាំ២០០៤ ក្ដីសង្ឃឹមអំពីការងារបានក្លាយជាការពិត ។ លោកបានធ្វើជាអ្នកយកព័ត៌មាន នៅកាសែតសំណេរថ្មី ជាកាសែតប្រចាំតំបន់មួយ នៅក្រុងព្រះសីហនុ ។ លោករៀបរាប់ដោយមោទនភាពថា ការងារជាក់ស្ដែង គឺដូចអ្វី ដែលលោកបានគិតជំនាញកាសែតនេះ គឺជាការពាំនាំព័ត៌មានពិត មិនលំអៀង និងមានប្រយោជន៍សម្រាប់អ្នកអាន" ។ លោកជា ប៊ុនធឿន សង្កត់ធ្ងន់



ថា : "គោលដៅរបស់ខ្ញុំ ធ្វើឱ្យចំណេញដល់អ្នកអានតាមរយៈអត្ថបទ ដែលផ្ដល់ព័ត៌មាន និងចំណេះដឹងដែលមិនលំអៀងនិន្នាការនយោបាយ សាសនា ពូជសាសន៍ ឬអ្វីឡើយ ។"

លោកជា ប៊ុនធឿន បានចែករំលែកនូវបទពិសោធន៍របស់លោកថា ការងារអ្នកសារព័ត៌មានមានឧបសគ្គចម្បងពីរ គឺការជ្រើសរើសប្រធានបទ និងមិនអាចទំនាក់ទំនងរកអ្នកឆ្លើយបាន ។ ការជ្រើសរើសប្រធានបទ គឺយើងអាចដោះស្រាយបានដោយដើរប្រឡូកសង្គម និងស្រាវជ្រាវមើលឯកសារ ឱ្យបានច្រើន ។ សម្រាប់ប្រភពព័ត៌មាន យើងត្រូវទាក់ទងមនុស្សឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ។ បើម្នាក់មិនឆ្លើយ យើងរកអ្នកថ្មី មកជំនួស ។






ទស្សនីយភាពមួយក្នុងការសម្ដែងនៅមហោស្រពចេនឡា
Photo : Piseth

# សិល្បៈខ្មែរបុរាណក្នុងទឹកចិត្តយុវជនបច្ចុប្បន្ន

ខាន់ ភីរម្យ

ស្របពេលសេដ្ឋកិច្ចរបស់ប្រទេសកាន់តែមានការរីកចម្រើនហើយការយល់ដឹងពីពិភពខាងក្រៅកាន់តែបានទូលំទូលាយ យុវជនខ្មែរវ័យក្មេងមួយចំនួនហាក់ដូចជាមិនសូវជាចាប់អារម្មណ៍នឹងសិល្បៈខ្មែរដែលមានលក្ខណៈបុរាណនោះឡើយ ។

ទិដ្ឋភាពទាំងអស់នេះ គេអាចមើលឃើញច្បាស់នៅក្នុងមហោស្រពសិល្បៈអាស៊ានមួយ ដែលគេរៀបចំសម្ដែងពីល្ខោនស្បែកពណ៌រឿងកូរសមុទ្រទឹកដោះ និងអាយ៉ៃរឿងស្រ្តីកញ្ជើធ្លុះក្នុងរឿងមារយើង ជូនសាធារណៈជនទូទៅ ទស្សនាដោយមិនគិតប្រាក់ ។

ទស្សនីយភាពនេះ រៀបចំដោយមជ្ឈមណ្ឌលវប្បធម៌បារាំងនៅឯមហោស្រពចេនឡា កាលពីថ្ងៃទី៧ ខែតុលាកន្លងទៅនេះ ។

ជាទូទៅនៅក្នុងពេលចាប់ផ្ដើម គេសង្កេតឃើញថា មានទស្សនិកជនជាច្រើនបាននាំគ្នាទៅចូលទស្សនាយ៉ាងពេញៗ តែក្រោយពីកម្មវិធីសម្ដែងចាប់ផ្ដើមឡើងបានកន្លះម៉ោងឡើងទៅ គេបានសង្កេតឃើញមនុស្សចាប់ផ្ដើមចេញជាបណ្ដើរៗ ដោយភាគច្រើនជាយុវជន និងកុមារ ។

កុមារាសេង សោភ័ណ ជាសិស្សសាលាបឋមសិក្សាទួលស្វាយព្រៃ បាននិយាយថា ការសម្ដែងនេះអត់ល្អមើលដូចរឿងតុក្កតា និងរឿងសត្វចម្លែក ដែលគេធ្លាប់មើលទូរទស្សន៍ឡើយ ។

យុវជនលីសីហា សិស្សនៅវិទ្យាល័យសន្ធម៉ុក បាននិយាយថា មកមើលល្ខោនស្បែក និងអាយ៉ៃនេះគឺដូចជាមិនបានមកមើលអ៊ីចឹង ព្រោះរូបគេមិនបានចាប់អារម្មណ៍ឱ្យបានស៊ីជម្រៅឡើយ ដោយសារតែអត់ល្អមើល ដូចវីដេអូ នៅរោងកុនលុច្ស ។ សីហាបានបញ្ជាក់ថា : "រឿងបាញ់គ្នា រឿងខ្មោចល្អមើលជាងខ្ញុំអាចស្រែក មើលការសម្ដែងថ្ងៃនេះ គឺដូចជាម៉េចទេ អត់យល់អីសោះ" ។

លោកសេក សុភា ជំនួយការប្រធានសមាគមអភិរក្សសិល្បៈ និងវប្បធម៌ មានប្រសាសន៍ថា អ្វីដែលលើកឡើង ដោយយុវជន និងកុមារខាងលើនេះ គឺមិនខុសនោះទេ ។ លោកបន្តទៀតដែរថា កុមារនិងយុវជនសម័យនេះ ភាគច្រើនមិនសូវចាប់អារម្មណ៍អំពីសិល្បៈបុរាណឡើយ ។ លោកបានបញ្ជាក់ថា : "ប្រសិនរាំញាក់និងរាំបុរាណ ពួកគេនឹងយករាំញាក់ ហើយបើសិនជាឱ្យគេមើលកុន និងមើលរបាំ ។ ពួកគេនឹងយកកុន" ។ លោកបានបន្តទៀតថា រហូតមកដល់ពេលនេះ លោកក៏ពិបាកស្វែងរកយុវជន ដែលមានការជាប់ចិត្តពិតប្រាកដទៅនឹងសិល្បៈបុរាណណាស់ ។ លោកក៏បានបញ្ជាក់ថា : "ខ្ញុំហ៊ានសន្និដ្ឋានថា មកដល់ពេលនេះ យុវជនដែលចេះមើលសិល្បៈបុរាណ មានប្រមាណជា ៣០%ប៉ុណ្ណោះ" ។

លោកបាននិយាយថា នេះជាគ្រោះថ្នាក់មួយចំពោះវប្បធម៌របស់ប្រទេសកម្ពុជា ដែលធ្លាប់មានតាំងពីបុរាណកាលមកដ៏យូរលុងមកហើយ ។ លោកបានបន្តទៀតថា ត្រង់ចំណុចនេះដើម្បីដោះស្រាយបញ្ហានេះ យុវជនកម្ពុជាគួរតែមានការយល់ដឹងច្រើនអំពីវប្បធម៌របស់ខ្លួន ហើយដើម្បីឱ្យយុវជនរឹតតែមានការយល់ដឹងនោះ គឺត្រូវតែមានការផ្សព្វផ្សាយ និងអប់រំ ។ លោកបាននិយាយថា កម្មវិធីសិល្បៈបុរាណគួរតែត្រូវបញ្ចូលទៅក្នុងកម្មវិធីសិក្សានៅក្នុងកម្មវិធីអប់រំចំណេះដឹងទូទៅ ។ លោកក៏បាននិយាយថា គេមិនចង់មើលដោយសារតែគេមិនទាន់យល់ ប៉ុន្តែបើគេធ្លាប់ដឹង និងយល់ខ្លះនោះ ពួកគេនឹងមានការចាប់អារម្មណ៍ចង់ដឹងបន្ថែមទៀត ។

កម្មវិធីសម្ដែងនេះ គឺជាផ្នែកមួយនៃកម្មវិធីសម្ដែងដែលមានរយៈពេលរហូតដល់ទៅ១សប្ដាហ៍ ដោយមានការចូលរួមសម្ដែងអំពីក្រុមសិល្បៈនានា មកពីបណ្ដាប្រទេសអាស៊ាន ។

November-2008.qxd 10/22/2008 2:17 PM Page 10

## បទយកការណ៍

# ទោះបីជាបារម្ភ ឪពុកម្តាយក៏ត្រូវកាត់ចិត្តបញ្ជូន កូនទៅឆ្ងាយ

**ខាន់ ភីរម្យ**

"កូននៅរៀនក្បែរខ្លួន ពួកខ្ញុំព្រួយទៅហើយ។ ដល់ពេលកូនទៅរៀន ឆ្ងាយពីផ្ទះអស់ ពួកខ្ញុំរឹតតែភ័យ ហើយព្រួយថែមមួយកម្រិតទៀត"។ នេះគឺជាសំដីរបស់ឪពុក និងម្តាយរបស់យុវនារីពីររូបដែលកំពុងបន្តការសិក្សានៅទីក្រុងភ្នំពេញ ក្រោយពេលដែលពួកនាងបានបញ្ចប់ការសិក្សាចំណេះទូទៅនៅខេត្តកំពង់ធំ ដែលជាខេត្តមួយចំងាយប្រមាណជា ១៦៨ គ.ម ខាងជើងទីក្រុងភ្នំពេញ ។

**ការព្រួយបារម្ភ របស់អាណាព្យាបាលយុវជន និងយុវនារីនៅជនបទ**

បងស្រីភីន ស៊ីណាត អាយុ៤៤ឆ្នាំ ជាអ្នកភូមិព្រៃកស្បូវ ឃុំអូរគន្ធរ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ មានប្រសាសន៍ថា សព្វថ្ងៃនេះគាត់មានកូនស្រីចំនួន ៣នាក់ ប៉ុន្តែគាត់បានបញ្ជូនកូនរបស់ពួកគាត់ ២នាក់ឱ្យទៅរៀននៅទីក្រុងភ្នំពេញរួចទៅហើយ បើទោះជានៅក្នុងកែវភ្នែក និងការយល់ដឹងរបស់គាត់ និងស្វាមីថា ទីក្រុងជាចំណុចភ្លើតភ្លើនស៊ីវិល័យ និងជាកន្លែងដែលញ៉ាំងឱ្យយុវជនមួយចំនួនងាយនឹងធ្លាក់ខ្លួន ទៅក្នុងអំពើអវិជ្ជមានយ៉ាងណាក៏ដោយ។ បងស្រីបានអះអាងថា គាត់ និងស្វាមី ពិតជាមានការព្រួយបារម្ភអំពីសុវត្ថិភាព និងជីវភាពរស់នៅរបស់កូនស្រីគាត់ទាំងពីរ ដែលត្រូវបន្តការសិក្សាឆ្ងាយពីផ្ទះឆ្ងាយពីភ្នែកឆ្ងាយពីការការពារ និងទំនុកបម្រុងរបស់គាត់ ដោយផ្ទាល់មែន ជាពិសេស ពេលដែលទទួលបានព័ត៌មានថា កូនអ្នកនេះខូច កូនអ្នកនោះខិល និងមានបញ្ហារហូតពេលត្រឡប់មកវិញ។ តែគាត់នៅតែកាត់ចិត្ត ដើម្បីអនាគតរបស់កូននៅក្នុងខណៈដែលគាត់ និងស្វាមី សុទ្ធតែជាអ្នកពុំបានរៀនសូត្រទាំងពីរនាក់នោះ។

បងស្រីស៊ីណាតបញ្ជាក់ថា: "ខ្ញុំពិបាកចិត្តរហូតដេកមិនលក់ជិតមួយឆ្នាំដោយភ័យនឹងកូន។ ខ្ញុំខ្លាចកូនស៊ីវិល័យ តាមគេ តាមឯង មិនគិតរៀន គិតតែដើរលេង។ កូននៅរៀនក្បែរផ្ទះងាយស្រួលការពារតែឆ្ងាយពីផ្ទះបានត្រឹមតែព្រួយបារម្ភ" ។

មិនឆ្ងាយប៉ុន្មានពីផ្ទះបងស្រីស៊ីណាត អ្នកមីងសឿន សុថុន អាយុ៤៨ឆ្នាំ ជាស្ត្រីមេម៉ាយ មានមុខរបរជាអ្នកលក់ដូរបន្តិចបន្តួចនៅមុខផ្ទះ ហើយសព្វថ្ងៃនេះបានបញ្ជូនកូនគាត់ទៅរៀននៅភ្នំពេញចំនួន ៤នាក់ បានបញ្ជាក់អំពីចំណាប់អារម្មណ៍ចំពោះការបញ្ជូនកូនឱ្យទៅរៀននៅទីក្រុង ក៏មិនសូវខុសគ្នាពីបងស្រីស៊ីណាតប៉ុន្មានដែរ។ អ្នកមីងបានមានប្រសាសន៍ថា សព្វថ្ងៃនេះ គាត់មានកូន ៦នាក់ តែគាត់បានបញ្ជូនកូន ៤នាក់ មករៀននៅភ្នំពេញទៅហើយ នៅក្នុងនោះ ស្រីពីរ ប្រុសពីរ ហើយសព្វថ្ងៃនេះ មានម្នាក់បានរៀនចប់និងមានការងារធ្វើរួចហើយដែលអាចចាត់ទុកថាជាគំរូដ៏ល្អមួយសម្រាប់ប្អូនៗ។

អ្នកមីង បានបន្តថា ពេលបញ្ជូនកូនទៅដំបូងសូម្បីតែពេលបាយក៏នឹកភ័យពីពួកគេផងដែរ ខ្លាចពួកគេទាំងអស់មិនគិតគូររៀនសូត្រ ចេះតែទារលុយយកទៅចាយវាយផ្តេសផ្តាសខូចអនាគត។ អ្នកមីងបានបញ្ជាក់ថា: "ខាងកូនស្រី ព្រួយខ្លាចភ្លើតភ្លើន មានសម្ភារៈអូសទាញ ចំណែកឯកូនប្រុសខ្លាច មានមិត្តភ័ក្ត្រភឿនអូសទាញ ភ្លេចរៀន វក់នឹងស្រា ល្បែង មានស្រីញី ដែលធ្វើឱ្យកើតជំងឺសង្គម" ។



ទោះនៅទីណា ក៏អ្នកម្តាយនៅនឹកកូនជានិច្ច

Photo : S. Philong

### ស្ថិតិស្ថាប័នបណ្តុះបណ្តាលថ្នាក់ឧត្តមសិក្សានៅទីក្រុងភ្នំពេញ

**តាមស្ថិតិពីក្រសួងអប់រំ បានឱ្យដឹងថា គិតរហូតមកដល់ពេលបច្ចុប្បន្ននេះ កម្ពុជាមានសកលវិទ្យាល័យ និងវិទ្យាស្ថានដែលកំពុងតែដើរតួនាទីជាស្ថាប័នអប់រំថ្នាក់ឧត្តម សិក្សាទាំងឯកជន និងរដ្ឋ សរុបទាំងអស់ ៧០ស្ថាប័ន ហើយមាននិស្សិតសរុបទាំងអស់ចំនួន ១៣៥០០០នាក់ បានចុះឈ្មោះចូលរៀន។ មន្ត្រីនាយកដ្ឋានឧត្តមសិក្សា មិនអាចទំនាក់ទំនងសុំស្ថិតិច្បាស់លាស់អំពីចំនួនស្ថាប័នឧត្តមសិក្សា ដែលមានទីតាំងនៅភ្នំពេញ និងចំនួននិស្សិតពីជនបទដែលមកចុះឈ្មោះសិក្សាបានឡើយ ប៉ុន្តែយោងតាមយោបល់របស់លោកឡៅ ឈីវអ៊ាង សកលវិទ្យាធិការនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ ភាគច្រើននៃស្ថាប័នឧត្តមសិក្សា មានទីតាំងនៅភ្នំពេញ។ លោកមានប្រសាសន៍ថា: "នៅក្នុងចំណោមនិស្សិតនៅសកលវិទ្យាល័យភូមិន្ទភ្នំពេញចំនួនជាង ១០០០០នាក់ មាននិស្សិតប្រមាណជា៦០% មកពីជនបទ"។**



នៅភូមិកំពង់ធំ ឃុំកំពង់រទេះ ស្រុកស្ទឹងសែន អ្នកមីងមួយរូប ឈ្មោះជឹម សុំ អាយុ ៥៣ឆ្នាំ មានមុខរបរដើរទិញអេតចាយ ក៏អះអាងថា គាត់មានកូនប្រុសបួននាក់ ក្រោយពីស្វាមីស្លាប់ទៅ គាត់នៅតែខិតខំបញ្ជូនកូនទៅរៀននៅឯភ្នំពេញ បានទាំងអស់គ្នា ប៉ុន្តែគាត់នៅតែមានអារម្មណ៍ភ័យព្រួយនឹងកូនជានិច្ច បើទោះបីជាគេអះអាងថា កូនគាត់សុទ្ធតែប្រុស មានអ្វីដែលត្រូវភ័យដូចជាកូនស្រីក៏ដោយ។ អ្នកមីងបានឱ្យដឹងថា ទោះស្រី ទោះប្រុស ក្នុងនាមជាម្តាយ ភ័យដូចតែគ្នាទេ ជាពិសេសពេលកូនទៅឆ្ងាយពីផ្ទះ។ អ្នកមីងបញ្ជាក់ថា: "កូនស្រីរបស់គេ គេភ័យខ្លាចភ្លើតភ្លើន ខូចខ្លួនប្រាណ ប៉ុន្តែកូនខ្ញុំមិនភ័យខូចខ្លួនទេ ប៉ុន្តែខ្ញុំភ័យរឿង គេដើរលេង ភ្លេចរៀន និងផ្តេសផ្តាសជាមួយស្រី នាំកើតអេដស៍" ។

**យោបល់អ្នកជំនាញ**

លោកឡៅ ឈីងអ៊ាងសកលវិទ្យាធិការនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ មានប្រសាសន៍ថា អ្វីដែលអាណាព្យាបាលយុវជន និងយុវនារីបានលើកឡើងខាងលើនោះ មិនខុសនោះទេ។ តែសុំកុំឱ្យពួកគាត់យកការព្រួយបារម្ភនោះ ធ្វើជាមូលហេតុមិនអនុញ្ញាតឱ្យកូនរបស់គាត់ មកសិក្សានៅភ្នំពេញឱ្យសោះ ពីព្រោះវាអាចធ្វើឱ្យប៉ះពាល់ដល់អនាគតរបស់ពួកគេ និងប៉ះពាល់ទៅដល់ផែនការអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងប្រទេសកម្ពុជា ។

លោកបានបញ្ជាក់ថា: "អ្នកបញ្ជូនកូន មករៀននៅភ្នំពេញ មិនខុសទេ ចំណែកឯអ្នកមិនបញ្ជូនកូនមកទើបជាអ្នកខុស។ អ្នកដែលខូចអនាគតនៅភ្នំពេញនោះ មានតែ១ ទៅ២នាក់ទេ ចំណែក ១០០០នាក់ គឺគេទៅមុខទាំងអស់" ។

លោកសុធី ជាមន្ត្រីនៃអង្គការក្រៅរដ្ឋាភិបាលដែលកំពុងតែធ្វើការជាមួយនឹងយុវជន មានប្រសាសន៍ថា យុវជន និងយុវនារី ដែលមកពីខេត្ត រៀននៅទីក្រុងភ្នំពេញ ពិតជាមានខ្លះៗកំពុងភ្លើតភ្លើន ហើយកំពុងធ្លាក់ខ្លួន ឱ្យសម្ភារៈអូសទាញរហូតដល់យុវនារីខ្លះ ហ៊ានរហូតដល់ធ្លាក់ខ្លួននៅក្នុងអំពើ ជួញដូរផ្លូវភេទ។ ខណៈដែលយុវជនខ្លះទៀត ធ្លាក់ខ្លួនប្រើប្រាស់គ្រឿងញៀន ហើយក៏មានខ្លះ ហ៊ានដល់ទៅប្រព្រឹត្តអំពើល្មើសផ្សេងៗដើម្បីជាថ្នូរនឹងភាពភ្លើតភ្លើន និងសម្ភារៈទាំងអស់នោះទៀតផង។ តែទោះជាយ៉ាងណា ភាគរយនៃករណីនេះមានតិចណាស់។

លោកបានបញ្ជាក់ថា : "ខ្ញុំមិនមានស្ថិតិមកបញ្ជាក់ទេ តែខ្ញុំហ៊ានអះអាងថា យុវជន និងយុវនារី ជ្រុលខ្លួនមានតិច ប៉ុន្តែពួកគេភាគច្រើន ដែលមកពីខេត្ត គឺមានអនាគតល្អ" ។

លោកអ៊ាង មានប្រសាសន៍ដែរថា បញ្ហាអវិជ្ជមានដែលកើតឡើងចំពោះលើយុវវ័យមួយចំនួននោះ គឺកើតឡើង ដោយសារតែការសេពគប់មិត្តភ័ក្តិ ការខ្វះភាពកក់ក្តៅ និងការអប់រំពីគ្រួសារ។ លោកបន្តទៀតថា គ្រួសារគឺសំខាន់ណាស់នៅក្នុងការចូលរួមតម្រង់ទិសដៅ របស់យុវជន និងយុវនារីទាំងអស់ មិនមែនសាលាទាំងស្រុងនោះទេ។

លោកបញ្ជាក់ថា : "សាលាជួយហើយ។ ប៉ុន្តែឪពុកម្តាយក៏ត្រូវជួយដែរទើបកូនរបស់ពួកគេទៅមុខ"។ បើផ្អែកតាមការយល់ឃើញនេះ អ្វីដែលលោកអ៊ាងបានលើកឡើងនោះ ហាក់ដូចជាមិនខុសពីយោបល់របស់បងស្រីស៊ីណាតបានលើកឡើងនោះទេ។

**បទពិសោធន៍ជាក់ស្តែង**

បងស្រីស៊ីណាត មានប្រសាសន៍ថា បើគិតមកដល់ពេលនេះ គឺគាត់បានបញ្ជូនកូនមករៀន នៅភ្នំពេញជិតប្រាំឆ្នាំហើយ ប៉ុន្តែឥរិយាបថ និងទម្លាប់នៃការរស់នៅរបស់កូនៗរបស់គាត់ គឺមិនមានអ្វីប្រែប្រួលឡើយ។ បងស្រីប្រាប់ថា បងស្រី និងស្វាមីបានមកលេងកូនញឹកញាប់ដែរ តែកូនរបស់គាត់នៅដដែល និងកាន់តែចេះដឹងជាងមុន។ នៅពេលគេចប់ គាត់រំពឹងថា នឹងអាចរកការងារធ្វើបាននៅភ្នំពេញ នឹងគេ។ បងស្រីបានឱ្យដឹងថា មូលហេតុដែលកូនរបស់បងស្រី មិនមានការផ្លាស់ប្តូរនោះ គឺដោយសារតែការអប់រំ និងការយកចិត្តទុកដាក់ពីគ្រួសារ។ បងស្រីបន្តដែរថា បងស្រីតែងព្យាយាមអប់រំកូន គ្រប់ជំហានពេលដែលជួបកូន និងតែងតែព្យាយាមផ្តល់ភាពកក់ក្តៅដល់ពួកគេរាល់ពេល ទោះបីជាពួកគេមិននៅក្បែរផ្ទះក៏ដោយ។

បងស្រីបញ្ជាក់ថា: "ខ្ញុំហៅទូរស័ព្ទយ៉ាងតិចម្តងនៅក្នុងមួយថ្ងៃដើម្បីសួរសុខទុក្ខ និងផ្តល់ភាពកក់ក្តៅដល់ពួកនាង"។ សព្វថ្ងៃនេះបើទោះជាបងស្រី មានការព្រួយបារម្ភយ៉ាងណាក៏ដោយ គាត់នៅតែអាចកាត់ចិត្តបញ្ជូនកូនស្រីរបស់គាត់ទាំងពីរឱ្យមករៀននៅភ្នំពេញបានជិតចប់ហើយ។ គាត់មានគម្រោងនឹងបញ្ជូន កូនស្រីពៅម្នាក់ទៀត នៅពេលដែលគេរៀនចប់ចំណេះទូទៅនៅកំពង់ធំ។

### សកលវិទ្យាល័យភូមិន្ទភ្នំពេញ

**សកលវិទ្យាល័យភូមិន្ទភ្នំពេញ គឺជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈមួយនៅក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សាទាំងរដ្ឋ និងឯកជនចំនួន ៧០ស្ថាប័ន នៅប្រទេសកម្ពុជា។ ស្ថាប័ននេះគឺជាស្ថាប័នអប់រំជាន់ខ្ពស់ធំជាងគេ នៅក្នុងប្រទេសកម្ពុជាជាមួយនឹងវត្តមាននិស្សិតចំនួនជាង ១០០០០នាក់។**

**លោកឡៅ ឈីវអ៊ាង សកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានប្រសាសន៍ថា ជារៀងរាល់ឆ្នាំសកលវិទ្យាល័យទទួលនិស្សិតអាហារូបករណ៍ (ផ្តល់ការសិក្សាដោយឥតបង់ប្រាក់) ប្រមាណ ៥៦០នាក់ ដោយនៅក្នុងនោះ ១០% ត្រូវបានផ្តល់ទៅនិស្សិតក្រីក្រ ១៥% ត្រូវផ្តល់ទៅនិស្សិតជានារីភេទ និង១០% សម្រាប់ផ្តល់ដល់និស្សិតដែលមកពីតំបន់ជនបទដាច់ស្រយាល់។ ក្រៅពីនេះគឺប្រឡងប្រកួតប្រជែង។ ក្រៅពីនិស្សិតអាហាររូបករណ៍ហើយនោះ សកលវិទ្យាល័យក៏ផ្តល់ឱកាសដល់និស្សិតដែលមានលទ្ធភាពបង់ថវិកាសិក្សាបានផងដែរ។ សកលវិទ្យាល័យភូមិន្ទភ្នំពេញកំពុងដំណើរការបណ្តុះបណ្តាលធនធានមនុស្សថ្នាក់ឧត្តមសិក្សា និងក្រោយឧត្តមសិក្សាលើ ៣មហាវិទ្យាល័យធំៗ គឺមហាវិទ្យាល័យវិទ្យាសាស្ត្រ មហាវិទ្យាល័យមនុស្សសាស្ត្រ និងសង្គមសាស្ត្រ និងវិទ្យាស្ថានភាសាបរទេស។**

# កសិកម្ម

## ការពារជំងឺ ដែលកើតលើដំណាំបន្លែ

### ថ្នាំពុលពីរុក្ខជាតិ_សេដាក

ក្នុងការដាំដុះបន្លែ កសិករតែងជួបប្រទះជំងឺ ដែលបំផ្លាញដំណាំ និងជំរុញឱ្យទិន្នផលដំណាំថយចុះ។ តាមរយៈសេដាក អ្នកនាំសារ ក៏សូមលើកយកបទពិសោធន៍ការពារជំងឺខ្លះ ដូចជា ជំងឺរលាក ជំងឺអុជ (ច្រែះ) និងជំងឺក្រាភ្លើងមកបង្ហាញ។

**ជំងឺរលាក**

បើតាមបទពិសោធន៍របស់កសិករបានប្រាប់ថា ជំងឺរលាកនេះអាចកើតឡើង ដោយសារស្រោចជី មិនបានលាងទឹកធម្មតា(ស្អាត) តាមពីក្រោយ។ មានភ្លៀងច្រើនពេក។ ដាក់ជីលើដំណាំនៅពេលដីសើមខ្លាំង។ ប្រើគម្របសើមដូចជាចំបើងសើម...។

រោគសញ្ញាជំងឺ : បែកញើសក្រោមស្លឹកកន្លែងដែលចេញញើសស្លោក និងបាក់រលួយ។

ដើម្បីការពារ ទប់ទល់នឹងជំងឺនេះ កសិករយកស្លឹកសង្កែ ឬស្លឹករាំងបុកឱ្យម៉ដ្តត្រាំទឹក។ រួចយកទឹកថ្នាំ ១០លីត្រនេះ លាយទឹកធម្មតា ១០លីត្រ បាញ់លើដំណាំ។ ក្តិចកន្លែងដែលកើតជំងឺចោល។គឺត្រូវយកទៅចោលឱ្យឆ្ងាយពីចំការនូវកំទេចកំទីសំរាម ដែលកើតជំងឺ។ យកស្លឹករាំងមួយតៅបុកឱ្យម៉ដ្ត លាយជាមួយនឹងចុងអង្គរបន្តិចយកទៅត្រាំទឹក។ បន្ទាប់មក យកទឹកថ្នាំ ១០លីត្រ លាយជាមួយទឹកធម្មតា ១០លីត្រ រួចបាញ់លើដំណាំ។


Photo : L. Samphors

**ជំងឺអុជ (ច្រែះដែក)**

មូលហេតុ គឺដីខ្វះជីជាតិ ពិសេស ជីអាសូត។ ប្រើជីគីមីស្រោចដំណាំ ដោយមិនបានលាងទឹក។ ជីក្តាំងនៅស្រទាប់លើ។ ក្រោយពីមានភ្លៀងធ្លាក់ហើយពុំបានស្រោចទឹកលាងទឹកភ្លៀងចេញ។

រោគសញ្ញាជំងឺនេះ មានលេចចេញជាអុជពណ៌ច្រែះលេចចេញនៅលើផ្ទៃស្លឹកនាផ្នែកខាងក្រោមរួចឆ្លងមកដល់ផ្ទៃស្លឹកផ្នែកខាងលើ។

ការពារ : ដើម្បីទប់ស្កាត់ជំងឺនេះ គួរបន្ថយការប្រើជីគីមី និងបង្កើនការប្រើជីធម្មជាតិឱ្យបានច្រើន។

**ជំងឺក្រាភ្លើង**

មូលហេតុ គឺដីខ្វះជីជាតិក្តាំងផ្នែកខាងក្រោម។ ទឹកច្រើនជោគជាំ។ អាកាសធាតុប្រែប្រួល មានខ្យល់ហប់ក្តៅ ដែលធ្វើឱ្យជំងឺនេះឆ្លងលឿន។

រោគសញ្ញា : ជំងឺនេះមានស្លឹកក្រហមរួញៗ (ដូចទំក្រៀប និងឆ្លងលឿននៅពេលអាកាសធាតុស្ងួត)។

ការការពារ : ត្រូវដករុក្ខជាតិកើតជំងឺចោល។ យកកំប្លោក ឬស្លឹកឈើងាប់ ដុតយកផេះបាចលើដំណាំ រួចក៏លាងផេះឱ្យស្អាត (ត្រូវបាញ់ទឹកលាងឱ្យច្រើន កុំខ្លាចដំណាំដួល)។

**បរិស្ថាន**

## ឡធ្យូងយ៉ូស៊ីម៉ូរ៉ា

ឡធ្យូងកែច្នៃដ៏ល្បីឈ្មោះ គឺឡយ៉ូស៊ីម៉ូរ៉ា ដែលជាបច្ចេកវិទ្យាដែលមកពីប្រទេសជប៉ុន ជាប្រភេទឡផលិតធ្យូង ដែលសមស្របសម្រាប់កម្ពុជា។


Photo : GERES Cambodia

ឡប្រភេទនេះអាចផលិតធ្យូងប្រកបដោយគុណភាពខ្ពស់ជាងឡបុរាណ។ ដើម្បីផលិតធ្យូង១គីឡូក្រាម ឡត្រូវការឈើតែ ៤,៥គីឡូក្រាម ប៉ុណ្ណោះ ដែលផ្ទុយពីឡបុរាណ ដែលត្រូវការធ្យូងរហូតដល់ ៦,៤គីឡូក្រាម។ មិនត្រឹមតែប៉ុណ្ណោះក្នុង សង្វាក់ផលិតកម្មធ្យូង ឡនេះអាចផលិតបានទឹកខ្មេះឈើ ដែលមានផលប្រយោជន៍យ៉ាងច្រើន សម្រាប់ប្រើប្រាស់វិស័យកសិកម្ម ដាំដុះដំណាំ។

ចុងឆ្នាំ២០០៣ដោយមើលឃើញសារៈប្រយោជន៍របស់ឡប្រភេទនេះ អង្គការក្រុមថាមពលកកើតឡើងវិញ បរិស្ថាន និងសាមគ្គីភាព ហៅ(**GERES Cambodia**) ក៏នាំយកបច្ចេកទេសពីគ្រូឯកទេសឥណ្ឌូណេស៊ុី ដែលបានទទួលនូវបច្ចេកវិជ្ជាធ្វើឡពីលោកយ៉ូស៊ីម៉ូរ៉ា មកដំណើរការនៅកម្ពុជា ពីព្រោះវាសមស្របសម្រាប់គម្រោងគ្រប់គ្រងព្រៃឈើ។

សព្វថ្ងៃនេះ **GERES Cambodia** បានសហការជាមួយសមាគមអភិវឌ្ឍន៍ចម្រុះនៃសហគមន៍ព្រៃឈើនៅឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវក្នុងការរៀបចំ "កម្មវិធីផលិតធ្យូង ប្រកបដោយនិរន្តរភាព"។ក្នុងកម្មវិធីនេះ អង្គការ **GERES Cambodai** បង្រៀនប្រជាពលរដ្ឋអំពីវិធីសាស្ត្រក្នុងការកាប់ព្រៃឈើ ការគ្រប់គ្រងព្រៃឈើនិងការផលិតធ្យូង។ គោលបំណងដ៏សំខាន់របស់កម្មវិធី គឺធ្វើឡធ្យូង តាមតំបន់ ដែលមានការរៀបចំដាំដើមឈើឡើងវិញ គឺចៀសវាងការកាប់ឈើខុសច្បាប់។

**ផាត សំភី**



# សុខភាព

## រើមប្រភេទជំងឺសើស្បែកឆ្លងមួយប្រភេទដែលបង្កគ្រោះថ្នាក់

### ខាន់ ភីរម្យ

លោកវេជ្ជបណ្ឌិតស៊ឹម សូផៃ អ្នកឯកទេសខាងជំងឺសើស្បែក និងកាមរោគ មានប្រសាសន៍ថា ជំងឺរើមជាប្រភេទជំងឺសើស្បែក និងឆ្លងមួយប្រភេទ។ ជំងឺនេះ គឺជាជំងឺដែលងាយព្យាបាល ហើយអាចជាជំងឺដែលគ្រោះថ្នាក់មួយប្រភេទដែរ។ ជំងឺនេះអាចកើតនៅលើស្បែកឬសរីរាង្គខាងក្នុងរបស់មនុស្ស។ លោកវេជ្ជបណ្ឌិត មានប្រសាសន៍បញ្ជាក់ថា រើមគឺជាប្រភេទជំងឺសើស្បែកមួយ ក្នុងចំណោម ជំងឺសើស្បែករាប់រយប្រភេទ ដែលគេរកឃើញថា វាបានកើតមានឡើងនៅលើស្បែករបស់មនុស្ស។ជំងឺនេះត្រូវបានគេរកឃើញ មានលើសពី ៩ប្រភេទ ។

លោកបានបញ្ជាក់ថា : "ជំងឺរើមមានច្រើនប្រភេទ តែតាមបទពិសោធន៍នៃការព្យាបាលរបស់ខ្ញុំកន្លងមក គឺរកឃើញថា មានចំនួនប្រមាណជា ៩ប្រភេទ ហើយវាច្រើនកើតមាននៅតាមគែមបបូរមាត់"។

លោកបន្តផងដែរថា ក្រៅពីកើតមាននៅតាមគែមបបូរមាត់ ហើយនោះវាក៏អាចកើតមានតាមកន្លែងផ្សេងៗ នៅលើស្បែកដោយរួមទាំងប្រដាប់បន្តពូជ ហើយក៏អាចកើតមាន នៅផ្នែកខាងក្នុងនៃសរីរាង្គរបស់មនុស្សផងដែរ។ រោគសញ្ញដំបូងនៃជំងឺនេះគឺអ្នកជំងឺមានអាការៈរោគក្តៅខ្លួន មានអារម្មណ៍ឈឺផ្សារតិចៗនៅកន្លែងដែលវាប្រុងកើត ហើយបន្ទាប់មកចាប់ផ្តើមមានពងបែកជាកញ្ចុំកើតមានឡើង។ ជំងឺនេះអាចកើតមាននៅលើខ្លួនមនុស្ស ដោយសារតែមេរោគមួយប្រភេទដែលគេអាចព្យាបាលបាន បើទោះជាវាមិនអាចព្យាបាលឱ្យជាដាច់ក៏ដោយ។ លោកក៏បានបញ្ជាក់ថា : "ព្យាបាលឱ្យជារោគសញ្ញបានតែព្យាបាលឱ្យដាច់ គឺមិនបានទេ"។ លោកបានបន្តទៀតថា យើងមិនអាចសម្លាប់មេរោគនេះ បានទេ តែយើងអាចគ្រប់គ្រងវាបានបើប្រព័ន្ធរាងកាយយើងនៅរឹងមាំ។

លោកបន្តទៀតថា ជំងឺនេះវាងាយឆ្លង ប្រសិនណាបើមានការប៉ះពាល់រវាងស្បែក និងស្បែក។ តែគេក៏អាចបង្ការបានដែរ តាមរយៈការធ្វើអនាម័យខ្លួនប្រាណ។ វិធីព្យាបាលវិញអាចធ្វើទៅបានតាមរយៈការប្រើប្រាស់ថ្នាំលាប និងលេប ក្រោយពីបានជួបពិភាក្សាជាមួយនឹងគ្រូពេទ្យជំនាញ។


Photo : S. Sophay

លោកព្រមានថា បើទោះបីជាវាជាប្រភេទជំងឺ សើស្បែកដែលងាយព្យាបាល ប៉ុន្តែអ្នកជំងឺគួរគប្បីជួបប្រឹក្សាជាមួយនិងគ្រូពេទ្យជំនាញ ឱ្យបានត្រឹមត្រូវ ព្រោះប្រសិនបើគ្មានការប្រឹក្សាយោបល់ត្រឹមត្រូវទេ អ្នកជំងឺអាចជួបវិបត្តិផ្នែកសុខភាពថ្មីៗទៀត។

## ទឹកដោះគោសម្លាប់កុមារ ៤រូប នៅចិន

**កុមារយ៉ាងហោចបួនរូប បានត្រូវរាយការណ៍ថា បានស្លាប់ និងរាប់ពាន់នាក់ទៀតកំពុងធ្លាក់ខ្លួនឈឺ ចាប់តាំងពីដើមខែតុលាកន្លងទៅនេះ ដោយសារតែការប្រើប្រាស់ម្សៅទឹកដោះគោ ដែលមានលាយឡំដោយសារធាតុគីមីមេឡាមីនលើសកម្រិតនៅប្រទេសចិន។**

**យោងទីភ្នាក់ងារសារព័ត៌មានអេភី បានឱ្យដឹងថា ដោយសារតែបញ្ហានេះ អាជ្ញាធរចិនបានចេញសេចក្តីប្រកាសរឹបអូសម្សៅទឹកដោះគោ និងផលិតផលទឹកដោះគោគ្រប់ប្រភេទចេញពីបណ្តាហាងនានានៅក្នុងប្រទេសចិន។**

**សារធាតុមេឡាមីននេះ គឺជាប្រភេទសារធាតុគីមី ដែលគេប្រើប្រាស់នៅក្នុងឧស្សាហកម្មវេចខ្ចប់។ គេបានរកឃើញ វាមាននៅផលិតផលជាច្រើនប្រភេទដែលផលិតពីទឹកដោះគោ។**

**សារធាតុមេឡាមីននេះ អាចធ្វើឱ្យមានបញ្ហាដល់គ្រលាន និងបញ្ហាសុខភាពចំនួនទៀតរបស់អ្នកប្រើប្រាស់ ជាពិសេសរបស់កុមារ។**

## បញ្ហាធ្មេញដែលដុះមិនត្រង់ជួរ


Photo : M. Kunthear

បើតាមប្រសាសន៍របស់ទន្តបណ្ឌិតឃុត មី នាយកគ្រប់គ្រងគ្លីនិកធ្មេញអន្តរជាតិ និងជាប្រធានគណៈទន្តពេទ្យរាជធានីភ្នំពេញ បានឱ្យដឹងថា :

ធ្មេញដែលដុះមិនត្រង់ជួរ ទៅមុខទៅក្រោយ វាជាធម្មជាតិ ប៉ុន្តែអាចមានមូលហេតុផ្សេងដែរ។ តាមធម្មតាពេលនៅក្មេង ធ្មេញតែងមានការផ្លាស់ប្តូរ។ ធ្មេញដំបូងរបស់មនុស្សគឺធ្មេញព្រៃ។ នៅអាយុ ៦ ឆ្នាំ ធ្មេញថ្គាមធំទីមួយ (ថ្គាមជ្រៅជាងគេបង្អស់) ដុះចេញមក។ ថ្គាមធំទី១ដុះតែម្តងក្នុងមួយជីវិត។ ប៉ុន្តែបើធ្មេញបន្តបន្ទាប់ដែលជាធ្មេញព្រៃឆាប់បាក់ពេក។ ថ្គាមធំទីមួយនេះអាចដុះលយទៅមុខ ដែលធ្វើឱ្យធ្មេញស្រុកដែលដុះមកក្រោយ ខ្វះទីតាំង ធ្វើឱ្យពួកវាដុះប្រជ្រៀតគ្នាទៅមុខទៅក្រោយ។

ធ្មេញដែលដុះមិនត្រង់ជួរនេះ ហុចផលប៉ះពាល់ទី១ គឺធ្វើឱ្យបាត់បង់សម្រស់លើផ្ទៃមុខ។ ទីពីរ ទាក់ទងនឹងការទំពារ ដែលមិនអាចឱ្យអាហារបានម៉ត់ល្អ។ ចំណែកទីបី ធ្មេញដុះពុំត្រង់ជួរ ឆាប់ពុកបាក់ណាស់ ព្រោះកំទេចកំទីចំណីអាហារងាយដកតែមធ្មេញ។

ការព្យាបាលធ្មេញដែលដុះមិនត្រង់ជួរនេះ គឺត្រូវធ្វើឡើងជាមួយទន្តបណ្ឌិតជំនាញ។ ការព្យបាល មានភាពងាយស្រួល និងលំបាក។ វិធីព្យាបាលសំខាន់គឺការពត់ធ្មេញ និងការវះកាត់។ ការព្យាបាលតាំងពីវ័យក្មេង គឺតែងមានប្រសិទ្ធភាពខ្ពស់ជាង។

លោកទន្តបណ្ឌិតឃុត មី ក៏រំឭកថា ឪពុកម្តាយភាគច្រើនគិតថា ធ្មេញព្រៃរបស់កូនមិនសំខាន់ទេ ចាំដុះធ្មេញថ្មីមក ទើបខំថែ។ តាមពិតធ្មេញព្រៃគឺសំខាន់ណាស់ ទីមួយ ធ្វើឱ្យក្មេង ទំពារបានល្អ មុនពេលដូរធ្មេញដូរ និងទី២ ជួយការពារធ្មេញដែលដុះមកថ្មីៗឱ្យដុះត្រង់ជួរល្អ។ លោកទន្តបណ្ឌិត ក៏ផ្តាំផ្ញើដែរថា សូមឪពុកម្តាយយកកូនទៅពិនិត្យធ្មេញជាមួយនិងទន្តបណ្ឌិតឱ្យបានទៀតទាត់ ដើម្បីបង្ការជាមុន។

**ផាត សំភី**

November-2008.qxd 10/22/2008 2:17 PM Page 14





Photo : DR

# បណ្តែតប្រទីប ពិធីបុណ្យ រំឭកដល់ព្រះពុទ្ធ និងព្រះគង្គា

**ខាន់ ភីរម្យ**

ពិធីបុណ្យបណ្តែតប្រទីបដែលប្រជាជនខ្មែរតែងតែនិយមប្រារព្ធធ្វើឡើង នៅពេលថ្ងៃលិច តាមបណ្តោយដងទន្លេសាប បន្ទាប់ពីពិធីប្រណាំងទូកងរៀងរាល់ខែវិច្ឆិកា ប្រចាំឆ្នាំនោះ ជាបុណ្យ ដែលប្រជាជនខ្មែររៀបចំឡើងដើម្បីរំឭកគុណទៅដល់ព្រះពុទ្ធ និងព្រះគង្គាដែលផ្តល់នូវជីវិត។

លោកសាស្ត្រាចារ្យមៀច ប៉ុណ្ណ ជាទីប្រឹក្សាអមក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅវិទ្យាស្ថាន ពុទ្ធសាសនិកបណ្ឌិត មានប្រសាសន៍ប្រាប់ឱ្យដឹងថា បណ្តែតប្រទីបនេះ គឺជាពិធីបុណ្យ មានតាំងពីយូរយារមកហើយ តាំងពីសម័យបុរាណ ដែលប្រជាជនខ្មែររៀបចំធ្វើឡើងដើម្បីរំឭក និងឧទ្ទិស ទៅដល់ព្រះចង្កោមកែវរបស់ព្រះពុទ្ធដែលប្រជាជនខ្មែរលោកមានជំនឿថា បានដង្ហែយកទៅរក្សាទុកនៅឋានភុជង្គនាគ។ អ្នកខ្លះទៀតថាគេរៀបចំឡើង គឺដើម្បីរំឭកទៅដល់ព្រះបាតរបស់ព្រះពុទ្ធ ដែលបានបន្សល់ទុកនៅស្ទឹងមួយនៅក្នុងប្រទេសឡាវ នាពេលបច្ចុប្បន្ននេះ។ ចំណែកអ្នកខ្លះទៀតបានយល់ថា គេប្រារព្ធឡើង គឺដើម្បីសម្តែងការគោរពទៅដល់ព្រះគង្គា និងក៏ដើម្បីធ្វើការសុំខមាលទោសចំពោះអ្វីដែលលើសលស់នៅក្នុងការប្រើប្រាស់ទឹក ដែលជាប្រភពដ៏សំខាន់ មិនអាចខ្វះបាន សម្រាប់ជីវិតមនុស្សសត្វ និងរុក្ខជាតិទាំងឡាយ ដែលមានជីវិត នៅលើលោក និងដើម្បីកំចាត់ចោលនូវភាពចង្រៃឧបទ្រពទាំងឡាយដែលកើតមាននៅក្នុងជីវិតរបស់ពួកគេប្រចាំថ្ងៃ។

លោកបញ្ជាក់ថា កាលពីដើមឡើយពិធីនេះពលរដ្ឋខ្មែរបុរាណជាច្រើន រៀបចំឡើងនៅពេលចេញវស្សា ដោយគេនិយមរៀបចំជាក្បូនដើមចេកតុបតែងជាមួយភ្លើងទៀន ឬចង្កៀង។ តែក្រោយមក គេបានច្នៃវាឡើងជាមួយនាវា បំពាក់ពន្លឺភ្លើងអគ្គិសនីទំនើប និងមានការតុបតែងលំអរទៅដោយ ពណ៌យ៉ាងសម្បូរបែប ហើយត្រូវបានគេច្របាច់បញ្ចូលគ្នាជាមួយនឹងពិធីបុណ្យផ្សេងទៀត មានពិធីបុណ្យប្រណាំងទូក អកអំបុក និងសំពះព្រះខែ ដែលធ្វើឡើងជារៀងរាល់ខែវិច្ឆិកា រហូតមកដើម្បីចំណេញពេលវេលា។ តាមការគ្រោងទុក ពិធីបុណ្យប្រណាំងទូក អកអំបុក និងសំពះព្រះខែ នៅក្នុងឆ្នាំនេះគ្រោងនឹងរៀបចំឡើងរយៈពេល បីថ្ងៃ ដូចជាសព្វមួយដង ដោយចាប់ផ្តើមពីថ្ងៃទី១១ រហូតដល់ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៨។

## អំណាន

### ជ្រោះអូរយ៉ាដាវ




ជារមណីយដ្ឋានធម្មជាតិដ៏ល្អត្រកាលនៅក្នុងភូមិភាគឦសាននៃប្រទេសកម្ពុជាយើង ហើយអ្នកនិពន្ធកាណែល ក៏បានយកឈ្មោះនេះ មកដាក់ជាចំណងជើងសម្រាប់រឿងប្រលោមលោករបស់គាត់ ដើម្បីរំឭកដល់អនុស្សាវរីយ៍កំសត់កម្រដែលគាត់ធ្លាប់មានជាមួយមិត្តភក្តិទាំងឡាយនៅលើទឹកដីនេះ។

រឿងជ្រោះអូរយ៉ាដាវ មានបង្កប់នូវព្រឹត្តិការណ៍សង្គម ជាច្រើននាសម័យលន់ នល់ ហើយអ្នកអានទាំងឡាយក៏នឹងមានអារម្មណ៍ថា ខ្លួនកំពុងតែអង្គុយស្តាប់លោកកាណែលនិទានរឿងឱ្យស្តាប់យ៉ាងជក់ចិត្ត។

តួអង្គមួយចំនួនធំក្នុងរឿងនេះ ទោះបីមិនមែន ជាមនុស្សត្រឹមត្រូវគ្រប់ដប់ ប៉ុន្តែសុទ្ធសឹងជាបុគ្គល ដែលមានវីរភាព និងមានការលះបង់គួរឱ្យគោរព។

រឿងនេះមានសភាពសម្បូរបែប ដែលធ្វើឱ្យអ្នកអានទាំងឡាយជក់ចិត្តជិតអារម្មណ៍ លើគ្រប់សកម្មភាព ព្រមទាំងគំនិតរបស់តួអង្គតាំងពីទំព័រទីមួយ រហូតដល់ទំព័របញ្ចប់។ សៀវភៅរឿងមានតំលៃប្រហែល ៥០០០រៀល និងមានកម្រាស់ ១៤៤ទំព័រ។

### នៅតែស្រឡាញ់



នៅតែស្រលាញ់ជាស្នាដៃរបស់អ្នកនិពន្ធវ័យចំណាស់ម្នាក់ គឺលោកកែវ យ៉ា។ លោកក៏លើកយករឿងហេតុទាំងឡាយ ដែលខ្លួនធ្លាប់បានដឹងឮមកចងក្រងជាប្រលោមលោកនេះឡើង។ ហេតុដូចនេះហើយទើបខ្សែរឿងនេះមានបង្កប់នូវចំណេះដឹងទូទៅជាច្រើនទាក់ទង ទៅនឹងស្ថានភាពរស់នៅរបស់សង្គមខ្មែរយើង កាលពីជាង ២ទសវត្សរ៍មុន។

ផ្នត់គំនិត ព្រឹត្តិការណ៍សង្គម និងព្រមទាំងចិត្តសាស្ត្ររបស់មនុស្សត្រូវបានលោកកែវ យ៉ា យកមកកែច្នៃធ្វើជាសាច់រឿងមួយដែលមានរសជាតិយ៉ាងសម្បូរបែប។ សុន្ទរីដែលជាតួអង្គឯកស្រីនៅក្នុងរឿងនេះ ជាមនុស្សដែលមានឆន្ទៈមោះមុតដើម្បីការកសាងវាសនារបស់ខ្លួន ប៉ុន្តែស្ថានភាពសង្គមមិនបានធ្វើឱ្យនាងមានឆាកជីវិត ដែលក្រាលដោយស្រទាប់ផ្កាកូឡាបនោះឡើយ។

តាមរយៈរឿងនេះ យើងអាចយល់ពីធម្មជាតិរបស់មនុស្សថា មនុស្សម្នាក់អាចល្អ អាចអាក្រក់ទៅតាមកាលៈទេសៈទៅតាមរបត់នៃជីវិតរបស់ពួកគេ តែជាទូទៅមនុស្សតែងស្រលាញ់ខ្លួនឯងមុននឹងស្រលាញ់អ្នកដទៃ។

**ម៉េង សុមនា**





# ថៃ មានអស្ថិរភាពនយោបាយធ្ងន់ធ្ងរ

**អាន ឡូរ៉ំ ប៉ូរ៉េ**

ព្រះរាជាណាចក្រថៃនៅគ្រាដំបូង ចាប់កំណើតនៅសតវត្សរ៍ ទី១៣ ដែលមានឈ្មោះថា រាជាណាចក្រសុខោទ័យ (Sukhothaï)។ ព្រះរាជាណាចក្រនេះមានទីតាំង នៅតាមដងទន្លេចៅប្រាយ៉ា ហើយបានអភិវឌ្ឍខ្លួន ដោយសារមានការគាំទ្រពីប្រទេសចិនជាមួយនឹងឱនភាពយ៉ាងធ្ងន់ធ្ងរនៃចក្រភពអង្គរ។ នៅចុងសតវត្សរ៍ទី១៤ ព្រះរាជាណាចក្របានផ្លាស់រាជធានីទៅកាន់ទីតាំងមួយកន្លែងទៀត គឺហៅថាអាយុធ្យា (Ayutthaya)។ ស្តេចនានានៃរាជធានីអាយុធ្យា បានរៀបចំព្រះរាជាណាចក្រ និងពង្រីកទឹកដី។ ប្រទេសសៀមក៏បានបើកចំហប្រទេសទៅរកឥទ្ធិពលរបស់បរទេស ជាពិសេសសម្រាប់វិស័យជំនួញ។ ប៉ុន្តែទំនាក់ទំនងជាមួយជនជាតិអ៊ឺរ៉ុប មានការលំបាក។ ជនជាតិសៀមនៅតែមិនទុកចិត្តពួកគេ។ នៅសតវត្សរ៍ទី១៨ ជាយុគនៃភាពអន់ថយ។ ជនជាតិភូមាបានវាយប្រហារ ហើយរាជាណាចក្រសៀមបានចុះចាញ់ និងបាត់បង់នៅឆ្នាំ១៧៦៧។ ប៉ុន្មានឆ្នាំក្រោយមក ស្តេចតាក់ស៊ីន (Taksin) បានសង្គ្រោះប្រទេសសៀមពីការបំផ្លាញ ឱ្យសាបសូន្យនេះ។ រាជវង្សចក្រីបានកាន់អំណាចបន្ត គឺបន្ទាប់ពីបានទម្លាក់ព្រះអង្គ ហើយបានទៅតាំងរាជធានីនៅបាងកក និងការពារអំណាចរហូតមក។ ការប្រកួតប្រជែងជាមួយប្រទេសវៀតណាមដើម្បីរក្សាឥទ្ធិពលលើប្រទេសកម្ពុជា គឺមានលក្ខណៈខ្លាំងក្លានៅដំណាក់សតវត្សរ៍ទី១៨ និងសតវត្សរ៍ទី១៩។




Photos : DR

### ព្រះមហាក្សត្រ : បុគ្គលមានប្រជាប្រិយភាពបំផុតនៅក្នុងប្រទេស



ភូមិបុល អាដុលយ៉ាដេត ត្រូវបានគេស្គាល់ក្រោមព្រះនាម រាមាទី៩ (Rama IX) គឺជាព្រះមហាក្សត្រដែលមានប្រជាប្រិយភាពបំផុតនៅក្នុងប្រទេសថៃ។ ព្រះអង្គឡើងគ្រងរាជ្យតាំងពីច្រើនជាង ៦០ឆ្នាំមកហើយ។ ព្រះអង្គប្រសូត្យនៅសហរដ្ឋអាម៉េរិក និងបន្តការសិក្សានៅប្រទេសស្វីស។ ព្រះអង្គមានអំណាចតិចតួចដោយហេតុថាប្រទេសដំណើរការទៅតាមប្រព័ន្ធរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។ ប៉ុន្តែជួនកាលព្រះអង្គធ្វើអន្តរាគមន៍នៅក្នុងជីវភាពនយោបាយដែលមានចលនានៅក្នុងប្រទេសថៃ។ ព្រះអង្គគឺជាអ្នកការពារឯកភាពជាតិដែរ។

ស្តេចរាមាទី៤ ចុះនូវសន្ធិសញ្ញាពាណិជ្ជកម្មជាច្រើនជាមួយបស្ចិមប្រទេស។ ប្រទេសថៃបានកែប្រែរូបរាងនិងទទួលបានទំនើបកម្ម។ ប្រទេសនេះការពារឯករាជ្យបាន ដោយបង់តម្លៃប្រគល់សងមកវិញនូវទឹកដីជាប្រយោជន៍សម្រាប់បារាំង (ខេត្តមួយចំនួនមានសៀមរាប និងបាត់ដំបង) មកឱ្យខ្មែរ។

នៅឆ្នាំ១៩៣២ គណបក្សប្រជាជនបានកាន់អំណាចគ្រប់គ្រងប្រទេស។ រាជានិយមដាច់ខាត់ក៏ត្រូវបានលុបបំបាត់ និងមានការប្រកួតប្រជែងនៅក្នុងបក្សប្រជាជនរវាងអ្នកអភិរក្សនិយម ដែលគាំទ្រដោយយោធា។ ដូច្នេះចាប់ពីពេលនោះ អ្នកបដិវត្តក៏បានកាច់ចង្កូតនយោបាយរបស់ប្រទេស។

ការបរាជ័យរបស់ប្រទេសបារាំងទល់អាឡឺម៉ង់នៅឆ្នាំ១៩៤០ ក៏ជំរុញឱ្យជនជាតិសៀមទាមទារ ទឹកដីដែលពួកគេសងខ្មែរ ត្រឡប់ទៅវិញ។ ពួកគេក៏បានជោគជ័យដោយមានការគាំទ្រពីជប៉ុន ហើយជាថ្នូរប្រទេស ទាំងពីរបានធ្វើជាសម្ព័ន្ធមិត្តនឹងគ្នា នៅក្នុងអំឡុងសង្គ្រាមលោកលើកទីពីរ។

នៅឆ្នាំ១៩៤៧ ជប៉ុនចាញ់សង្គ្រាមលោក។ ប្រទេសសៀមសងសាជាថ្មី នូវខេត្តនានា ដែលគេយកនៅឆ្នាំ១៩៤០ មកឱ្យខ្មែរវិញ។ ការសម្រេចនេះលំបាកនឹងទទួលយកដោយប្រជាជនសៀមខ្លះ។ ដូច្នេះពួកយោធាសម្រេចធ្វើរដ្ឋប្រហារ និងក៏បានជ័យជម្នះ។ នៅក្នុងប្រទេសក៏ដូចជាលើឆាកអន្តរជាតិ ប្រទេសថៃ បានប្រកាន់យកឥរិយាបថដាច់ខាតប្រឆាំងនឹងកុំម្មុយនីស្ត។ នយោបាយនេះបានរុញថៃឱ្យខិតជិតអាម៉េរិក ពិសេសក្នុងអំឡុងសង្គ្រាមវៀតណាម។

រហូតមកដល់ពេលនេះ រដ្ឋប្រហារយោធា ជាច្រើនបានកើតមានឡើង ជាមួយការផ្លាស់ប្តូររដ្ឋធម្មនុញ្ញជាច្រើនដែរ ប៉ុន្តែអំឡុងពេលមានស្ថិរភាពនយោបាយម្តងៗ បានអនុញ្ញាតឱ្យមានការអភិវឌ្ឍន៍ខាងសេដ្ឋកិច្ច។ ដំណើរការប្រជាធិបតេយ្យ និងកំណើនសេដ្ឋកិច្ចវិលមកវិញ ក្នុងទសវត្សរ៍១៩៨០ (បន្ទាប់ពីបរាជ័យ នៅឆ្នាំ១៩៧៣ និង១៩៧៦)។ សព្វថ្ងៃប្រទេសថៃមិនអាចបញ្ចប់អស្ថិរភាពនយោបាយ។ នេះហុចផលលំបាកយ៉ាងខ្លាំងដល់កម្ពុជា ធ្វើដំណើរការចរចាបញ្ហាព្រំដែនជាមួយប្រទេសនេះ។ រាល់ថ្ងៃនេះ ប្រទេសថៃក៏កំពុងប្រឈមមុខផងដែរទៅនឹងការបះបោលរបស់ក្រុមបំបែកខ្លួន និងអំពើហិង្សាសាសនានៅភាគខាងត្បូងប្រទេសដែលភាគច្រើននៃប្រជាជនជាអ្នកកាន់សាសនាឥស្លាម។

November-2008.qxd 10/22/2008 2:19 PM Page 16

# សារថ្វាយព្រះពរ



សូមក្រាបបង្គំទូលថ្វាយព្រះពរជ័យ
ថ្វាយព្រះករុណា ព្រះបាទសម្ដេច
ព្រះបរមនាថ នរោត្តមសីហមុនី
ព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា

ទូលព្រះបង្គំយើងខ្ញុំ ជាអភិបាល បូជាចារ្យ បព្វជិត បព្វជិតា រួមជាមួយគ្រីស្តបរិស័ទ
នៃព្រះសហគមន៍កាតូលិក នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
មានសេចក្តីសោមនស្សរីករាយ
សូមក្រាបបង្គំទូលថ្វាយព្រះពរសព្វសាធុការ
ថ្វាយព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
ក្នុងព្រះរាជពិធីរាជាភិសេក គម្រប់ ៤ព្រះវស្សា យាងចូល
៥ព្រះវស្សា
ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាសូមអធិដ្ឋានទូលអង្វរព្រះជាម្ចាស់
ដ៏មានឫទ្ធានុភាពសព្វប្រការ
សូមទ្រង់ព្រះមេត្តាប្រសិទ្ធពរជ័យ បវរប្រសើរ
ថ្វាយព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
សូមព្រះករុណាបានប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន
ព្រះបញ្ញាញាណភ្លឺថ្លាត្រចះត្រចង់ ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់លើសិរីរាជបល្ល័ង្ក
ជាម្លប់ដ៏មហាត្រជាក់ត្រជុំសុខក្សេមក្សាន្ត
ចម្រុងចម្រើនរុងរឿង ដល់ប្រជានុរាស្ត្ររបស់ព្រះអង្គ ជានិច្ចនិរន្តរ៍តរៀងទៅ ។
សូម ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង
ទ្រង់ព្រះមេត្តាទទួលនូវគារវភក្តីដ៏ខ្ពង់ខ្ពស់
និងយ៉ាងជ្រាលជ្រៅបំផុតពីព្រះសហគមន៍កាតូលិកនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ភ្នំពេញ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៨

លោក អេមីល ដេតម្ប
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា

## ការងារប្រចាំខែ

- ថ្ងៃទី២៤-២៩ តុលា : មានកិច្ចប្រជុំអាស៊ីអំពីពិធីបុណ្យក្នុងព្រះសហគមន៍កាតូលិក ស្តីអំពីអគ្គសញ្ញាអាពាហ៍ពិពាហ៍ ដែលប្រារព្ធធ្វើនៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។ សម្រាប់កម្ពុជា មានលោកបូជាចារ្យប៉ូលរឿង អាត់ឆៃ ជាដឹកនាំគណៈប្រតិភូ។
- ថ្ងៃទី៣១ តុលា ដល់ថ្ងៃទី២ វិច្ឆិកា : មានការប្រគុំតន្ត្រីក្លាស៊ិក (បុរាណ) អន្តរជាតិ នៅព្រះវិហារសន្តយ៉ូសែប ភ្នំពេញ។
- ដើមខែវិច្ឆិកា : ចាប់ផ្តើមសាងសង់សាលាមត្តេយ្យ នៅកោះស្លានៅខេត្តកំពត មានឈ្មោះថា សន្តប៉ូល។
- ខែវិច្ឆិកា : មានការសាងសង់សាលាមត្តេយ្យនៅឃុំត្រែងត្រយឹង ជាការឧបត្ថម្ភពីព្រះសហ-គមន៍ក្រុងព្រះសីហនុ។
- ថ្ងៃទី៤ វិច្ឆិកា : ពិធីសម្ពោធមណ្ឌលកុមារនៅព្រះសហគមន៍កំពង់ឃ្លាំង ខេត្តសៀមរាប។
- ថ្ងៃទី៩ ខែវិច្ឆិកា : បុណ្យឯករាជ្យជាតិ។
- ថ្ងៃទី៩ ខែវិច្ឆិកា : មានការដង្ហែគ្រប់សាសនាទាំងអស់នៅប្រទេសកម្ពុជារៀបចំដោយក្រសួងធម្មការ និងនៅទីក្រុងភ្នំពេញ។
- ថ្ងៃទី១១-១៣ វិច្ឆិកា : ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ។
- ថ្ងៃទី១១-១៣ វិច្ឆិកា : សិក្ខាសាលាគ្រូអប់រំជំនឿរៀបចំដោយមជ្ឈមណ្ឌលវប្បធម៌កាតូលិក។
- ថ្ងៃទី១៦ វិច្ឆិកា : បូជាចារ្យក្រុមសហជីវិនព្រះយេស៊ូជួបជុំគ្នាសំណាក់ធម៌នៅព្រះសហគមន៍ក្រុងព្រះសីហនុ រយៈពេល១០ថ្ងៃ។
- ថ្ងៃទី១៩-២២ វិច្ឆិកា : សិក្ខាសាលាគ្រូមត្តេយ្យសម្រាប់ភូមិភាគភ្នំពេញ ធ្វើនៅព្រះវិហារសន្តយ៉ូសែប ភ្នំពេញ។
- ថ្ងៃទី២៥ វិច្ឆិកា : ប្រជុំប្រធានក្រុមបូជាចារ្យក្រុមគ្រូសារសាសនទូត និងប្រធានក្រុមអ្នកស្ម័គ្រចិត្តនៅគេហដ្ឋានលោកអភិបាលភ្នំពេញ។
- ថ្ងៃទី២៦-២៧ វិច្ឆិកា : ប្រជុំបូជាចារ្យ និងបងស្រីភូមិភាគកំពង់ចាម នៅព្រះសហគមន៍ដាក់ដាំ និងប៊ូស្រា ខេត្តមណ្ឌលគិរី។
- ថ្ងៃទី២៦-២៩ វិច្ឆិកា : ប្រជុំបូជាចារ្យនិងបងស្រីភូមិភាគបាត់ដំបង នៅព្រះសហ-គមន៍សៀមរាប។
- ថ្ងៃទី២៧-២៨ វិច្ឆិកា : ការជួបប្រជុំលោកតាលោកយាយ និងចាស់ៗ នៅព្រះសហ-គមន៍តាអំ ខេត្តសៀមរាប។